# មជ្ឈមណ្ឌលឯកសារកម្ពុជា

## ចាន់ សុខ (ហ) សារឿន I09493

## ជួបសម្ភាសជាមួយ ប្អូនប្រុសឈ្មោះចាន់ គា អាយុ៤៣ឆ្នាំ

## រស់នៅភូមិឈើភ្លើង ឃុំកំពង់ត្រាច់ ស្រុករមាសហែក ខេត្តស្វាយរៀង

## ថ្ងៃទី៣០ខែ សីហា ឆ្នាំ២០០៥

## សម្ភាសដោយៈ អ៊ីសា ខស្នាន

ខស្នានៈ សួរបង! ដំបូងខ្ញុំចង់ស្គាល់ឈ្មោះបងសិន បងឈ្មោះអីដែរបង?

គាៈ ចាន់ គា ។

ខស្នានៈ ចាន់ ឆា?

គាៈ ចាន់ គា ។

ខស្នានៈ ចាន់ គា?

គាៈ បាទ ។

ខស្នានៈ បងអាយុប៉ុន្មាន?

គាៈ អយុ៤៨ឆ្នាំ ។

ខស្នានៈ សព្វថ្ងៃបងនៅភូមិអី?

គាៈ ភូមិឈើភ្លើង ។

ខស្នានៈ បាទ?

គាៈ ភូមិឈើភ្លើង ។

ខស្នានៈ ភូមិជាភ្លើង?

គាៈ បាទ ។

អ្នកជិតខាងៈ ភូមិឈើភ្លើង ។

ខស្នានៈ ឈើភ្លើង ។ ឃុំ?

គាៈ ឃុំកំពង់ត្រាច ។

ខស្នានៈ ស្រុករមាសហែកហ្នឹង?

គាៈ ស្រុករមាសហែក ។

ខស្មានៈ បាទ ចុះភូមិឈើភ្លើងមានឈ្មោះ មានឈ្មោះហៅក្រៅផ្សេងទៀតទេ?

អ្នកជិតខាងៈ ហៅក្រៅភូមិយើងឯណោះផ្សេងទេ តែគេដាក់អញ្ចុះឥឡូវចូលទៅតាដក់ ។

គាៈ តាដក់ ។

ខស្មានៈ ហៅតាដក់ហ៎?

គាៈ តាដក់ ។

ខស្មានៈ ចុះពីដើមគេហៅថាយ៉ាងម៉េចទៅ?

គាៈ ហៅតាដក់តាម្តង ។

ខស្មានៈ ហៅតាដក់ ។ ចុះមកហៅឈើភ្លើងនៅពេលណាអញ្ចឹង?

គាៈ ហៅឈើភ្លើងពីជំនាន់ ជំនាន់យើងផ្លាស់ទៅលិចដឹងជំនាន់ប៉ុន្មានទៅវ៉ុ ។ អើយើងត្រឡប់មកវាម្តងមកវា មនុស្សតិចពេកគេភ្លាប់គ្នា ។

ខស្មានៈ ឱ!ភូមិឈើភ្លើងទៅ?

គាៈ បាទ ។ គេបញ្ចូលខាងឈើភ្លើងទៅ ។ គេថាយើងវាតិច ។

ខស្មានៈ ហេតុអីបានមនុស្សតិជាងមុន?

គាៈ មនុស្សគេបញ្ជូនទៅស្លាប់អស់នោះ ។

ខស្មានៈ អ្នកណាអ្នកបញ្ជូនទៅ ជំនាន់ណា?

គាៈ ដឹងពីណា?

ខស្មានៈ ជំនាន់ណាដែលគេបញ្ជូនមនុស្សទៅលិចហ្នឹង ជំនាន់ឥឡូវសម្តេច ជំនាន់ខ្មែរក្រហម ឬជំនាន់ណា?

គាៈ ជំនាន់ខ្មែរក្រហម ។

ខស្មានៈ ជំនាន់ខ្មែរក្រហមណ៎? ឪពុកម្តាយឈ្មោះអីបង?

គាៈ ឪពុកឈ្មោះចាន់ ជីម ។

ខស្មានៈ ចុះម្តាយ?

គាៈ ម្តាយឈ្មោះអ៊ុក ដាន់ ។

ខស្មានៈ បាទ បងមានបងប្អូនប៉ុន្មាននាក់ដែរ?

គាៈ បងប្អូនមានប្រាំនាក់ ។

ខស្មានៈ ប្រាំនាក់? នៅសព្វថ្ងៃនៅទាំងប្រាំនាក់ដែរ?

គាៈ សព្វថ្ងៃនៅតែម្នាក់ហ្នឹង ។

ខស្មានៈ ឪ!

គាៈ ស្លាប់អស់បួន ។

ខស្មានៈ បាទ បួននាក់ដែលស្លាប់ហ្នឹងឈ្មោះអីខ្លះទៅ?

គាៈ បួននាក់ដែលស្លាប់ហ្នឹង ទីមួយឈ្មោះ ចាន់ សុខ ទីពីរឈ្មោះ សុមាលី, ទីបីឈ្មោះ ចាន់ សឿន, ទីបួនឈ្មោះ ចាន់ ហឿន ។ បងប្អូនស្លាប់ទាំងអស់ហ្នឹង ។

ខស្មានៈ បាទ អីចាន់ សុខប្រុសឬស្រី?

គាៈ ចាន់ សុខប្រុស ។

ខស្មានៈ ចុះអ្នក អ្នកបីនាក់ទៀត?

គាៈ បងគេហើយចាន់ សុខហ្នឹង ។

ខស្មានៈ បាទហើយ ។

គាៈ ហើយបន្ទាប់មកសុមាលីហ្នឹងស្រី ។

ខស្មានៈ ស្រី?

គាៈ បាទ ។ ហើយបន្ទាប់មកទៀតហ្នឹងចាន់ សឿនហ្នឹងប្រុសដែរ ។ បន្ទាប់មកទៀត ចាន់ ហឿនហ្នឹងប្រុសដែរ ។

ខស្មានៈ ប្រុសដែរ?

គាៈ បាទ ។

ខស្មានៈ អី បងប្អូនបួននាក់ហ្នឹងស្លាប់ពីពេលណា?

គាៈ ស្លាប់ៗជំនាន់ប៉ុល ពតទាំងអស់តែហ្នង ។

ខស្មានៈ ស្លាប់ជំនាន់ប៉ុល ពត?

គាៈ បាទ តែបងប្រុសស្លាប់មុនគេ ម៉ាជំនាន់ គឺថាម៉ាជំនាន់សោភីមណ៎ ។

ខស្មានៈ អីបាទ បងប្រុសណាបង?

គាៈ បងខ្មៅហ្នឹងណ៎?

ខស្មានៈ ឱបងឈ្មោះចាន់ សុខ?

គាៈ ចាន់ សុខ ។

ខស្មានៈ ចាន់ សុខហ្នឹង ។ ដឹងថាគាត់មានឈ្មោះអីគេហៅផ្សេងទៀតទេ?

អ្នកជិតខាងៈ ហ្នឹងហៅម៉ៅណ៎?

គាៈ ហៅម៉ៅ?

ខស្នាន: មានដឹងថាគាត់មាន?

គា: កំណើតដើមឈ្មោះ អត់បានស្គាល់ទៀតទេ ។ តែទៅធ្វើការគាត់ឈ្មោះទៀត តែអត់បានស្គាល់ ។

ខស្នាន: អឺ ចុះបីនាក់ទៀតគាត់ស្លាប់ក្រោយនេះ បងប្អូន..?

គា: ស្លាប់ក្រោយប៉ុល ពតហ្នឹងដែរ ។

ខស្នាន: ក្រោយ ប៉ុល ពត បាន័យថាចប់ ប៉ុល ពត ហើយបានគាត់ស្លាប់យ៉ាងម៉េច?

គា: ស្លាប់ម៉ាជំនាន់គេបញ្ជូនទៅហ្នឹង ។

ខស្នាន: ឪ! ចុះនៅរស់ម្នាក់ហ្នឹងបងប្អូន?

គា: ខ្ញុំនៅរស់បន្ទាប់ទីបី ។

ខស្នាន: ប្អូនបងអ្នា?

គា: ប្អូនបង ។

ខស្នាន: ឈ្មោះអី?

គា: ឈ្មោះចាន់ គាហ្នឹង ។

ខស្នាន: ឪ! អញ្ចឹងរាប់ទាំងខ្លួនឯងហ្នឹងអ្ន?

គា: បាទ រាប់ទាំងខ្លួនឯង ។

ខស្នាន: បាទ អញ្ចឹងនៅសព្វថ្ងៃនៅតែម្នាក់ ខ្លួនឯងហ្នឹង ។

គា: ខ្លួនឯងមួយទេ ។

ខស្នាន: បាទ ។ អឺខ្ញុំចង់ដឹងពីរឿងរ៉ាវរបស់បងឈ្មោះចាន់ សុខណ៌ ។ ពីតូចមកគាត់រៀនបាន កម្រិតណាដែរ?

គា: ពីតូចវារៀនបានកម្រិត ចប់ថ្នាក់សាលាកូលេសពីដើមវាចប់ដែរ ។ សាលាកូលេសថ្នាក់ទី១០អីអញ្ចឹង ។

អ្នកជិតខាង: ថ្នាក់ទីប៉ុន្មានក៏គាត់រៀនចប់ដែរបានគាត់ចូលធ្វើការ ។

ខស្នាន: គាត់រៀនសាលាកូលេសអ្នំ?

គា: ការសិក្សាគាត់ខ្ពស់ដែរ ។

ខស្នាន: ឪ! ថ្នាក់ទីប៉ុន្មានទៅ?

គា: ពីដើមថ្នាក់ទី១២អស់ហើយ ។

អ្នកជិតខាង: ថ្នាក់ទីប្រាំ, ទីប្រាំអស់ហើយហ្នំ? អស់ហើយអស់រលីង ។

គា:		រៀនចប់ថ្នាក់ត្រឹមហ្នឹងហើយ ។

ខស្មានៈ		អឺ រៀនចប់ថ្នាក់នៅស្រុកហ្នឹង សាលាកូលេស?

គា:		បាទ ។

ខស្មានៈ		ឪប្ដូមហើយនៅសាលាកូលេស?

អ្នកជិតខាងៈ	ឪប្ដូមហើយតើ ។

ខស្មានៈ		អញ្ចឹងបានន័យថាគាត់ជាប់ឪប្ដូមហើយ?

អ្នកជិតខាងៈ	គាត់ជាប់ឪប្ដូមហើយ ។ គាត់ចេះណាស់ ។

គា:		គាត់ទៅប្រឡងនៅស្វាយរៀង ។

ខស្មានៈ		គាត់ចេះភាសាបរទេសទេ? គាត់ចេះភាសាបារាំងអីទេ?

អ្នកជិតខាងៈ	គាត់នេះភាសាយួននោះគាត់ចេះទាំងអស់ ។

គា:		ហើយពីដើមគាត់មាន គាត់ចេះតិចៗទេយ៉ាងមើលទៅ ។ ខ្ញុំមិនបានទាន់ដែរ វានៅតូចដែរណាស់ ។

ខស្មានៈ		បាទ ចុះបងប្អូនបីនាក់ទៀត ដែលស្លាប់ហ្នឹងចេះដឹងដូចគាត់អញ្ចឹងដែរឬក៏គាត់ទេចេះជាងគេក្នុងចំណោមបងប្អូន?

គា:		គាត់ចេះដែរ គាត់ពេទ្យដែរ បងស្រីសុមាលីហ្នឹងណា៎ ។ ចេះពេទ្យ ។

ខស្មានៈ		ធ្វើពេទ្យសម័យណា?

គា:		ធ្វើពេទ្យជំនាន់នោះ ។

ខស្មានៈ		សម័យខ្មែរក្រហម?

គា:		បាទ ។ មុនហ្នឹងបន្តិច ។

ខស្មានៈ		អញ្ចឹងអឺ គាត់រៀន បងចាន់ សុខហ្នឹងគាត់ចេញពីសាលាមកគាត់ធ្វើការអីខ្លះទៅ?

គា:		ចេញពីសាលាគាត់ទៅធ្វើទាហានហ្នឹងហ្មង ចេញពីទាហានគាត់ធ្វើពេទ្យ ។

ខស្មានៈ		ឪ!គាត់ធ្វើទាហាន?

គា:		បាទ ។

ខស្មានៈ		ទាហានខាងណាទៅ?

គា:		ទាហានយើង ខាងយើងហ្នឹងអ្ហ៎ ។

ខស្មានៈ	នៅសម័យហ្នឹងមានពីរ ទាហានមានទាហានខាងលន់ នល់ ហើយមួយទៀតទាហានខាងរំដោះដែលរំដោះ តែក្រោយមកគេហៅថាខ្មែរក្រហមណា៎ស តើគាត់ទាហានខាងណាដែរ?

គាៈ	ទាហាន ទាហានខាងហ្នឹងហ្នង?

អ្នកជិតខាងៈ	ប្រជាជន, រំដោះជាមួយប្រជាជន ។

ខស្មានៈ	ឪ!ទាហានខាងរំដោះអ្ហ៊ូ?

គាៈ	មិនមែនខ្មែរក្រហមទេកាលនោះ ។

ខស្មានៈ	នៅពេលគាត់ចូលធ្វើទាហានហ្នឹងគាត់អាយុប៉ុន្មានដែលគាត់ចេញរៀនមកហ្នឹង?

គាៈ	គាត់ចូលធ្វើទាហានប្រហែលជាអាយុ៣០ ឆ្នាំហើយ ។

ខស្មានៈ	អាយុ៣០ជាងហើយ?

គាៈ	បាទអយុ៣០ជាងកាលចូលធ្វើទាហានហ្នឹង ។

ខស្មានៈ	គាត់មានប្រពន្ធមានកូនហើយនៅ?

គាៈ	គាត់មើល ។ មានហើយនៅបង?

អ្នកជិតខាងៈ	មិនទាន់មានទេអាអូននៅតូចដែរ ។

គាៈ	និយាយបងណា អាយុបងណា៎?

អ្នកជិតខាងៈ	អឺវាមានប្រពន្ធហើយតែវាមិនទាន់ដល់៣០ទេ ។

គាៈ	គិតមើល គាត់មានប្រពន្ធហើយបានគាត់ទៅអញ្ចឹងហ្អី?

អ្នកជិតខាងៈ	មានប្រពន្ធហើយ ។

ខស្មានៈ	មានប្រពន្ធហើយ? មានប្រពន្ធមានកូនហើយ?

អ្នកជិតខាងៈ	មានប្រពន្ធហើយ មានកូនហើយ ។

ខស្មានៈ	មានកូនប៉ុន្មាននាក់?

គាៈ	កូនគាត់ពីរនាក់ ។

ខស្មានៈ	ប្រពន្ធគាត់ឈ្មោះអីដែរ?

គាៈ	ស្អីយឿងម៉េច យឿងម៉េចស្អីទេហ្អី ។

ខស្មានៈ	ឈ្មោះយឿន?

គាៈ	អើឈ្មោះមិនដឹងថាម៉េចស្អីយឿន ។

ខស្មានៈ	បាទចុះអ្នកស្រុកណាដែរ?

គាៈ នៅបុស្សកប្បាសហ្នឹង ។

ខស្មានៈ នៅបុស្សកប្បាស?

គាៈ បាទនៅបុស្សកប្បាសហ្នឹង ។

ខស្មានៈ អញ្ចឹងបានន័យថាគាត់ចេញពីសាលាមកគាត់អត់ទាន់ចូលធ្វើទ័ពភ្លាមទេ
ព្រោះគាត់មានប្រពន្ធសិន?

អ្នកជិតខាងៈ

គាត់ចេញពីសាលាមកគាត់នៅរកស៊ីបានមួយឆ្នាំអីហ្នឹងបានចាប់ផ្ដើមគេត្រូវការទាហានហ្នឹង គាត់ចូលទាហាន ហ្នឹងតែម្ដង ។ ធ្វើទាហានហ្នឹងរបួសម៉ាសាហើយហ្នឹងគេឲ្យឈប់គាត់ក៏ចូលខាងពេទ្យ ។ ចេញពីខាងពេទ្យហ្នឹង ហើយចេញពីខាងទេពទ្យហ្នឹងហើយបាននៅចូល នៅចូលរោងចក្រនៅភ្នំពេញ ។ ហ្នឹងគាត់ពិការហើយ ។

ខស្មានៈ ខ្ញុំចង់ដឹងពីគាត់ ធ្វើទាហានហ្នឹងណា៎ តើមូលហេតុអីដែរបានគាត់ចូលធ្វើទាហានអញ្ចឹង?

គាៈ ដឹងមូលហេតុអីកាលហ្នឹងមូលហេតុគាត់ចិត្តអញ្ចឹងគាហ្នងយ៉ាង ។

ខស្មានៈ គាត់ស្ម័គចិត្ត?

គាៈ បាទ ។

ខស្មានៈ ហើយនៅក្នុងបងប្អូនរបស់បង អ្នកផ្សេងទៀតមានចូលធ្វើទាហានជាមួយគាត់អញ្ចឹងទេ?

គាៈ អត់មានផង មានតែមួយ ។

ខស្មានៈ មានតែគាត់?

គាៈ មានតែគាត់ទេ ។

ខស្មានៈ អញ្ចឹងអ្នកភូមិហ្នឹងដូចថាមិត្តភ័ក្រគាត់
ឬក៏អ្នកដែលស្របាល ៗ គាត់ហ្នឹងមានចូលដូចគាត់ចឹងដែរ?

គាៈ មានចូល មានចូលដូចគ្នា ។ ផ្ទះនេះមួយឥឡូវមកវិញហើយ ឥឡូវពិការដៃ ។ ហ្នឹងនៅក្រុមហ៊ុនជាមួយគ្នាហ្នឹង ។

ខស្មានៈ ឪ! ទៅជាមួយគ្នា?

គាៈ បាទនៅជាមួយគ្នា ។

ខស្មានៈ ទៅ ទៅនៅភ្នំពេញជាមួគ្នាដែរឬអត់ទេ?

គាៈ ខុសគ្នា ។

ខស្មានៈ ខុសគ្នា គាត់ឈ្មោះអី?

គាៈ ស្អីសាយទេនេះ?

អ្នកជិតខាងៈ កែវ ៗ

គាៈ ក្បាត ឈ្មោះក្បាតតែមិនដឹងអីក្បាតទេ ។

ខស្មានៈ សាត ប្រុសឬស្រី?

គាៈ ប្រុស ។

ខស្មានៈ នៅភូមិនហ្នឹង?

គាៈ ភូមិហ្នឹងឈ្មោះ.....។ ហ្នឹងទៅមាស្រករគ្នាហ្នឹង ។

ខស្មានៈ ឪ! ស្រុកកំណើតគាត់នៅហ្នឹងដែរ?

គាៈ នៅហ្នឹងដែរហ្នឹង ផ្ទះហ្នឹងខស្សព្រាហ៍ឡើងចុះជាមួយគ្នាហ្នឹង ។

ខស្មានៈ បាទ អឺខ្ញុំចង់ដឹងពីសម័យហ្នឹង ខ្ញុំឮតែគេថាមានអ្នកស្ម័គ្រចិត្តចូល ចូលធ្វើទាហានច្រើនណា៎ អឺ! ខ្ញុំដូចជាឆ្ងល់ថាម៉េច បានជានៅក្នុងសម័យនោះចូលចិត្តទាហាន ចូលចិត្តធ្វើទាហានណា៎ មូលហេតុអ្វីដែរ?

គាៈ មូលហេតុកាលជំនាន់មុននោះហ្នឹងអ្ហ៎?

ខស្មានៈ បាទ បាទ សម័យខ្មែរក្រហមហ្នឹងណា៎?

គាៈ ខ្ញុំមិនបានដឹងដែរ ។

ខស្មានៈ បាទ ៗ អញ្ចឹងខ្ញុំសូមសួរបងបន្តទៀត ។ ខ្ញុំចង់ដឹងថាហេតុអីបានជាពេលហ្នឹងមានយុវជនក៏ដោយ យុវនារីក៏ដោយ គឺចូលចិត្តធ្វើទាហានហ្នឹង ដោយសារបញ្ហាអីដែររឿងហ្នឹង? អត់ដឹងទេហ៎?

គាៈ អត់ដឹង ។

ខស្មានៈ បងនៅក្មេង?

គាៈ បាទនៅក្មេង ។ កាលណោះក្មេងពេក ។

ខស្មានៈ ហើយអឺ ពេលដែលគាត់ចូលធ្វើទាហាឈ្មោះចាន់ សុខហ្នឹងគាត់ចូលធ្វើទាហាននៅកន្លែងណា?

គាៈ ស្វាយរៀង ។

ខស្មានៈ នៅស្វាយរៀង?

គាៈ ចូលស្វាយរៀងកាលណោះ?

អ្នកជិតខាងៈ អត់ដឹងទេ ។ មិនដឹងដែរហ្នឹង ។

ខស្មានៈ បងមានដឹងដែរ?

គាៈ គ្រាន់តែថាគាត់ទៅស្វាយរៀងហ្នឹង ។

ខស្មានៈ បាទ ហើយគាត់ធ្វើទាហានបានរយៈពេលប៉ុន្មានទៅ? បាទក្រោយមកគាត់ថា បងថាគាត់ធ្វើពេទ្យវិញអ្ហ៎? ត្រូវទេអញ្ចឹង?

គាៈ បាទ ។

ខស្មានៈ អញ្ចឹងរយៈពេលប៉ុន្មានដែរគាត់បានធ្វើទាហានហ្នឹង?

គាៈ មិនដឹងថាដឹងប៉ុន្មានទេ ។

ខស្មានៈ បាទអត់អីទេបង អីចុះពេលដែលគាត់ធ្វើពេទ្យមូលហេតុអី?

គាៈ មូលហេតុពីគាត់ពិការ ។

ខស្មានៈ គាត់ពិការ ពិការយ៉ាងម៉េចទៅ?

គាៈ ពិការត្រូវជើង ។

ខស្មានៈ ត្រូវជើង?

គាៈ បាទ ។ ដល់ទៅវាយត្រូវជើងគាត់ចូលខាងពេទ្យមក ។

ខស្មានៈ ជើងឆ្វេង ជើងស្តាំ?

គាៈ ជើងឆ្វេងកាលហ្នឹង ។

ខស្មានៈ ហើយគាត់ពិការហ្នឹង គាត់អាចជើងហ្នឹងប្រើការបានដែរឬក៏ពិការប្រើមិនបាន?

គាៈ ជើងប្រើបាន ប្រើបាន ។

ខស្មានៈ គ្រាន់តែរបួសអាចនៅប្រើបានដែរ?

គាៈ របួសហ្នឹងដើរជើងបី ដល់ពេលក្រោយមកហ្នឹងគាត់បានដើរបានវិញ ។

ខស្មានៈ ដឹងថាគាត់ទៅធ្វើសង្រ្គាមនៅកន្លែងណាដែលគាត់ពិការហ្នឹង?

គាៈ អត់បានដឹងច្បាស់ដែរសង្រ្គាមមិនដឹងនៅកន្លែងណាទេ?

ខស្មានៈ បាទ ចុះអីនៅពេលដែលគាត់ពិការគាត់ចូលធ្វើពេទ្យនៅកន្លែងណាដែរបង?

គាៈ ចូលធ្វើពេទ្យនៅក្រុងភ្នំពេញហ្នុង ។

ខស្មានៈ ពេទ្យនៅក្រុងភ្នំពេញហ្នុង?

គាៈ បាទ ។

ខស្មានៈ ម៉េចបានបងដឹង ។

គាៈ អើដែលគាត់ធ្លាប់មកលេងគាត់ថាធ្វើការ ធ្វើពេទ្យនៅភ្នំពេញ ។

ខស្មានៈ គាត់ថាធ្វើពេទ្យនៅភ្នំពេញ?

គាៈ បាទ ។

ខស្មានៈ ខ្ញុំចង់ដឹងឆ្នាំដែលគាត់ចូលធ្វើទាហានហ្នឹងប្រហែលជាឆ្នាំប៉ុន្មានដែរ?

អ្នកជិតខាង: ប្រហែលជាក្រោយ៧០ហើយ ។

ខស្មានៈ ពេលនោះអឺ ដូចរដ្ឋប្រហារទម្លាក់សម្ដេចឪប៉ុន្មានឆ្នាំ បានគាត់ធ្វើអឺ ចូលធ្វើទាហានហ្នឹង?

គាៈ ឆ្នាំប៉ុន្មានទេកាលហ្នឹង ខ្ញុំមិនបានដឹងទេ ។

ខស្មានៈ ចុះនៅពេលដែលគាត់ចូលធ្វើពេទ្យហ្នឹង ពេលហ្នឹងនៅភ្នំពេញហ្នឹង ខាងកម្លាំងខ្មែរក្រហមវាយបានភ្នំពេញហ្នឹងហើយ?

គាៈ បែកហើយ បែកគេហៅទៅ ។ ទេមុនហ្នឹង មុនគាត់ខស្សាហ៍មកលេងមុននោះមួយមីងនោះអុះជាមួយ ពូនោះ?

ខស្មានៈ បែកភ្នំពេញហើយពេលនោះ?

គាៈ មុន ធ្វើពេទ្យមុន ។

ខស្មានៈ មុនបែកភ្នំពេញ?

គាៈ បាទ ។

ខស្មានៈ បែកភ្នំពេញបែកជំនាន់ណា បងចង់និយាយថាបែកជំនាន់ណា? ខ្ញុំចង់អ្វីដែលខ្ញុំចង់សួរគឺបែកឆ្នាំ៧៥ពេលដែលប្រជាជនជំលៀសចេញពីភ្នំពេញណ៎? តើពេលដែលគាត់ចូលធ្វើពេទ្យហ្នឹងខ្មែរក្រហមវាយបានភ្នំពេញ, ជម្លៀសប្រជាជនពីភ្នំពេញហើយនៅ?

គាៈ មុនហ្នឹង ។

ខស្មានៈ មុនហ្នឹងទៀតអេ្ហ?

គាៈ បាទ ។

ខស្មានៈ អញ្ចឹងបានន័យថាគាត់មិនធ្វើពេទ្យនៅភ្នំពេញទេពីព្រោះកាលហ្នឹងនៅភ្នំពេញខាង លន់នល់ អ្នកគ្រប់គ្រងទេ?

អ្នកជិតខាង: ប្រហែលជាទៅតាមទ័ព្វហ្នឹង ទៅតាមទ័ព្វរំដោះហ្នឹងទេ ។ តែគាត់ចេញចូលៗ ។

ខស្មានៈ តែគាត់ គាត់ខស្សាហ៍មកលេងផ្ទះដែរ?

គាៈ បាទ ។ គាត់ខស្សាហ៍មកដែរពីរឆ្នាំបីឆ្នាំគាត់មកម្ដងដែរ ។

ខស្មានៈ ឳ! គាត់ធ្វើពេទ្យហ្នឹងជំនាញគាត់ខាងអីទៅ?

គាៈ	មិនដឹងជំនាញខាងម៉េចទេ ប៉ុនគាត់ថាឈប់ពីធ្វើមេបញ្ជារការហ្នឹងគាត់មកធ្វើពេទ្យម្តង ។

ខស្មាន	អញ្ចឹងពេលដែលគាត់ធ្វើពេទ្យហ្នឹង គាត់ជាអ្នកអី ជាមេបញ្ជារការដែរ?

គាៈ	បាទ ។

ខស្មានៈ	បញ្ជារការថ្នាក់ណាដែរ?

គាៈ	បែបត្រឹមតត្រឹមអីហ្នឹងមិនដឹង ។

ខស្មានៈ	ហើយក្រោយមកគាត់ចូលធ្វើពេទ្យ?

គាៈ	បាទ, ហើយគេថាពេទ្យហ្នឹង នៅក្រុមហ៊ុននៅហ្នឹងហ្នងនៅភ្នំពេញហ្នងគាត់ថាអញ្ចឹងអ្ហា ។ ហើយបានវា ទទួលបែបគេដូរស់ទៅបាត់ចឹងទៅក៏គាត់ស្លាប់ហ្នឹងណា ។

ខស្មានៈ	ឱ! ហើយពេលណាដែលគាត់មកលេងចុងក្រោយគេ ដូចថាមកចុងក្រោយគេនៅពេលណា?

គាៈ	មកឆ្នាំប៉ុន្មានទេ ។

ខស្មានៈ	ឆ្នាំប៉ុន្មាន?

គាៈ	វាដូចជាចាំមិនសូវច្បាស់សោះ ។ វាមិនដឹងឆ្នាំប៉ុន្មានខែប៉ុន្មានខ្ញុំវាមិនបានចេះកាលណោះវានៅក្មេងភ្លើ ដែរហ្នឹង ។

ខស្មានៈ	អត់ដឹង មិនចាំទេ?

គាៈ	មិនចាំផង ។

ខស្មានៈ	ចុះនៅពេលដែលគាត់ចូលធ្វើពេទ្យឬក៏បានធ្វើទព័អីហ្នឹង ដូចប្រធានសហករណ៍អី នៅតាមស្រុកភូមិនេះ, ប្រធានភូមិ, ប្រធានក្រុម បងហ្នឹងគេមានកោតខ្លាចគ្រួសារបងខ្លះទេ? ដោយសារថាបានគាត់ធ្វើធំអញ្ចឹង?

គាៈ	គាត់មានថាអីបងប្អូនប្រជាជនស្រុកហ្នឹង, គាត់មានតែធ្មេច ។ អប់អរទាំងអស់តែគ្នាទៅ ។

ខស្មានៈ	ដូចថាគេ ដូចថាចំពោះបងអីគេមានគិតថាជាគ្រួសារមួយ ពិសេសបានគុណបំណាច់ដោយសារតែមានបងប្អូនបានទៅធ្វើទ័ព, ធ្វើពេទ្យអីអញ្ចឹង គេមានលើកពីបញ្ហាហ្នឹងដែរ?

គាៈ	បាទ, គ្មានលើកអីផង ។

ខស្មានៈ	អត់ទេ?

គាៈ	បាទ ។

ខស្មានៈ អញ្ចឹងអីនៅពេលចុងក្រោយដែលគាត់មកលេងជាមួយបង មកលេងជាមួយក្នុងគ្រួសារ ហ្នឹងគាត់បាននិយាយថាម៉េចពេលដែលគាត់ចេញទៅ ហើយបាត់ខ្លួនគាត់ហ្នឹង?

គាៈ គ្មានបាននិយាយថាម៉េចទេក៏គាត់ទៅវិញទៅ ។ ស្រាប់តែស្ងាត់ៗចឹងតាហ្មងទៅ ។

ខស្មានៈ ស្រាប់តែស្ងាត់ទៅ?

គាៈ បាទ ។

ខស្មានៈ ហើយពេលដែលគាត់មកលេងម្ដងគាត់អី មានអីធ្វើដំណើរមក?

គាៈ មកឡាន ម៉ូតូ ។

ខស្មានៈ គាត់ជិះឡានមក ជិះម៉ូតូមក?

គាៈ បាទ ។

ខស្មានៈ មានអង្គរក្សមានអីការពារទេ?

គាៈ បាទមានដែរ ។

ខស្មានៈ មានដែរ?

គាៈ មាន ។ មកម្ដងម៉ូតូចឹងទៅ អាមកចុងក្រោយហ្នឹងឡាន ។

ខស្មានៈ មកចុងហ្នឹងក្រោយជិះឡានមក?

គាៈ បាទ ជិះឡានមក ។

ខស្មានៈ ហើយគាត់ធ្វើធំអញ្ចឹងពេលដែលគាត់មកម្ដង គាត់មានអីផ្ញើរមកបងប្អូនច្រើន?

គាៈ មានសម្ភារៈ តាំងពីផ្លែឈើ ផ្លែអីហ្នឹងសព្វមុខចឹងណាស់ ។

ខស្មានៈ ឱ!

គាៈ តាំងពីថ្នាំរបស់របរអីដូចថាអីចឹងទៅហូបចុកចឹងណា ។

ខស្មានៈ បាទ, ចុះអីដូចប្រធានសហករណ៍អីហ្នឹង ប្រធានភូមិអីហ្នឹងគាត់បានមកជួបនិយាយគ្នាដែរ ពេលហ្នឹង, ពេលដែលគាត់មកលេងម្ដងៗ?

គាៈ មានអីមកនិយាយលេងប្រាជ្ញអីមក និយាយលេងធម្មតាអញ្ចឹងទៅ គាត់ដើរលេងបងប្អូន អីធម្មតាអញ្ចឹងទៅ ។

ខស្មានៈ បាទៗ ។

គាៈ ហើយម្យ៉ាងកាលនោះខ្ញុំវានៅក្មេងខ្ចីដែរមិនបានរាក់ទាក់និយាយពីរឿងអីៗ វាមិនបានចាំ ច្បាស់ ។

ខស្នាន: អឺនៅពេលបន្ទាប់ពីគាត់ដែលខាន់មិនបានមកលេងហ្នឹងអ្ហា បងដែលបានទទួលដំណឹងអីពីគាត់ឬក៏បានទទួលសំបុត្រអីពីគាត់យ៉ាងម៉េចទេ?

គា: អត់ដែលបានទទួលផងតាំងពីបានគាត់ខ្លួនហ្នឹងទៅ ស្ងាត់ឈឹងតាហ្នឹង ។

ខស្នាន: ចុះមកដល់សព្វថ្ងៃមានរូបថតគាត់អីនៅសល់ទេ?

គា: អត់មានផង ។

ខស្នាន: អត់មានទេ?

គា: បាទអត់បានទុករូបថតអី ទទេហ្នឹង ។

ខស្នាន: ឱ, ចុះបងគិតយ៉ាងម៉េចនៅពេលបាត់គាត់ អត់ឃើញគាត់មកលេងអញ្ចឹង?

គា: សួរដំណឹងដែរ ។

ខស្នាន: សួរដំណឹងដែរ សួរតាមណាទៅ?

គា: អើសួរអ្នកដែលធ្លាប់ទៅធ្វើការគាត់បានមកវិញអញ្ចឹងទៅចេះតែសួរទៅៗ ។ ហើយដូចសួរបងផ្ទះឯជើង គាត់ថាបានជួបគ្នាដែរដល់ពេលថ្ងៃដែលគាត់ចេញមកហ្នឹងទៅវាស្ងាត់ទាល់តែបែកគ្នាទល់ ផ្លូវហ្នឹងទៅ លែងបានជួបទៅ ។

ខស្នាន: គាត់ថាបានជួបនៅឯណា?

គា: នៅក្លៀងរាយ ។

ខស្នាន: នៅឯណាទៅក្លៀងរាយ?

គា: ក្លៀងរាយឯណា លិចភ្នំពេញចឹងអី?

ខស្នាន: ជួបនៅពេលណា ឆ្នាំណា?

គា: ខ្ញុំអត់បានស្គាល់ផង ។ អត់បានស្គាល់ឆ្នាំ ។

ខស្នាន: បាទ, អឺ! ចុះក្រោយៗមកទៀតបងគិតថាយ៉ាងម៉េច នៅពេលដែលអត់ឃើញគាត់ត្រឡប់មកអញ្ចឹងបង គិតថាគាត់ស្លាប់ហើយឬគាត់អាចនៅរស់នៅកន្លែងណាមួយ?

គា: ខ្ញុំសង្ស័យថាគាត់ស្លាប់តែម្ដងព្រោះបាត់យូរពេកហើយ ។

ខស្នាន: សង្ស័យថាស្លាប់ប៉ុន្តែអត់ទាន់ច្បាស់?

គា: បាទ អត់ទាន់ច្បាស់ ។

ខស្នាន: បាទ ខ្ញុំយកមកឲ្យបងនេះគឺប្រវត្តិរូបដែលគាត់ជាប់គុកទួលស្លែងណាស់ ។

គា: បាទ ។

ខស្ទានៈ គេចាប់គាត់ដាក់កគុកទួលស្លែង ហើយធម្មតាគុកហ្នឹងគឺកម្រមានអ្នករួចខ្លួនណាស់ ។ អញ្ចឹងប្រហែលជាគាត់ស្លាប់ពេលដែលគេចាប់គាត់ដាក់គុកទួលស្លែងហ្នឹងហើយ ។ អញ្ចឹង នៅពេលដែលខ្ញុំមកប្រាប់បងដំណឹង ហ្នឹងអញ្ចឹង បងមានអារម្មណ៍យ៉ាងម៉េចដែរ បងគិតថាឈប់ចាំគាត់តទៅទៀតហើយឬក៏យ៉ាងម៉េច?

គាៈ អើបើគាត់ស្លាប់ហើយទៅចាំធ្វើម៉េចកើត?

ខស្ទានៈ ចុះនៅពេលដែលពីមុន មុនពេលដែលខ្ញុំមកប្រាប់ដំណឹងហ្នឹងណា៎ បងអត់ទាន់ច្បាស់បងសង្ស័យថាគាត់ អាចនៅរស់ ឬក៏អាចស្លាប់ហើយនៅពេលដែលខ្ញុំមកប្រាប់ គឺច្បាស់ថាគាត់ស្លាប់ហើយ?

គាៈ បាទ ។

ខស្ទានៈ អញ្ចឹងពេលនេះហើយប្រៀបធៀបពេលមុនហ្នឹងដែលបងអត់ទាន់ច្បាស់ហ្នឹង តើអារម្មណ៍បងយ៉ាងម៉េចដែរ? ដូចថាពេលដែលគិតដឹងច្បាស់ទៅ ដូចថាធូរក្នុងអារម្មណ៍ ឬក៏កាន់តែនឹកនាដល់គាត់ឡើងវិញ?

គាៈ អឺគ្រាន់ថាអាណិតហ្នឹងអ្ហា ប៉ុន្តែមិនដឹងធ្វើម៉េចទេកាត់ៗទៅ ។

អ្នកជិតខាងៈ ខំតែអរស្មានតែនៅរស់ ។

ខស្ទានៈ បាទ អឺខ្ញុំចង់ត្រឡប់មកសួរពីរឿងរ៉ាវផ្ទាល់ខ្លួនរបស់បងម្តងណាស់?

គាៈ បាទ ។

ខស្ទានៈ មិញហ្នឹងខ្ញុំបានសួរពីប្រវត្តិរបស់គាត់បានដឹងខ្លះហើយ ហើយខ្ញុំចង់សួរពីបងម្តង ។ បងចាំបានអីខ្លះ នៅពេលដែលខ្មែរក្រហមចូលមកគ្រួតត្រានៅក្នុងភូមិហ្នឹងដំបូងមក? បងចាំយ៉ាងម៉េចខ្លះទៅ ឬក៏បងនៅអាយុតិចពេកអត់ចាំ?

គាៈ វាមិនសូវចាំតែម្តង អាយុវាក្រែលដែរហើយប៉ុន្តែវាមិនបានសូវចាំច្បាស់ ។

ខស្ទានៈ ខ្ញុំចង់សួរបងថាពេលដែលខ្មែរក្រហមចូលមកក្នុងភូមិរបស់បងដំបូងហ្នឹង, តើវាខ្មែរក្រហមហ្នឹងរៀបចំការគ្រប់គ្រងតាមភូមិឃុំ ឬក៏ជីវភាពប្រជាជនអីខុសប្លែកពីមុនមកយ៉ាងម៉េចដែរទេ?

គាៈ មិនបានសូវចេះទេ ។

ខស្ទានៈ បាទអត់អីទេបង ។

ហើយអញ្ចឹងពេលដែលសម័យហ្នឹងគេប្រើបងធ្វើអីខ្លះខ្ញុំចង់ដឹងកន្លែងហ្នឹង?

គាៈ សម័យណា?

ខស្នាន: សម័យខ្មែរក្រហម ។

គា: សម័យខ្មែរក្រហមគេប្រើឲ្យខ្ញុំជីកដី រែក កាប់ លើកប្រឡាយ ភ្លឺស្រែអីហ្នឹង ។

ខស្នាន: ក្រុមរបស់បងដែលធ្វើការហ្នឹងគេហៅក្រុមអី?

គា: គេហៅកងចល័តណាំ ។

ខស្នាន: គេហៅកងចល័ត?

គា: បាទ ។

ខស្នាន: កងចល័តហ្នឹង អ្នកដែលគេយកចូលកងចល័តហ្នឹង ពីអាយុប៉ុន្មានដល់អាយុប៉ុន្មាន?

គា: ពីអាយុប៉ុន្មានទៅកាលនោះប្អូនដប់ឆ្នាំអី?

អ្នកជិតខាង: ពីពីរដណ្ដប់ឡើងទៅ ។

គា: ពីពីរដណ្ដប់ឡើង ។

ខស្នាន: ចាប់អីអាយុ១២ឆ្នាំឡើង?

អ្នកជិតខាង: គេយកចូលតែកុមារ ឲ្យតែកុមារចូលកងចល័ត ។

ខស្នាន: ហើយដល់អាយុប៉ុន្មាន ដល់អាយុប៉ុន្មានទៅ ១២ឆ្នាំដល់អាយុប៉ុន្មានឆ្នាំដែលគេឲ្យចូលក្នុងកងចល័ត?

គា: អាយុ៥០ អឺមើ ។

ខស្នាន: បងគិតថាអ្នកដែលនៅក្នុងកងជាមួយគ្នាហ្នឹងណាស់ ដល់អាយុប៉ុន្មានដែលនៅកងចល័តហ្នឹង?

គា: យកត្រឹមពីអាយុ១២ឆ្នាំដល់ ។

ខស្នាន: ដល់អាយុប៉ុន្មាន?

គា: អើយើងធ្វើបានប៉ុន្មានឆ្នាំបាន.... ។

អ្នកជិតខាង: មិនមែនទេ យកត្រឹមអាយុដប់ជាងត្រឹមកុមារៗនេះឯង គេចាត់ទៅរើសដីរើសអីចឹងឯង ។ អើគេយកពីអាយុ១២រហូតដល់ងអាយុ.... ។

ខស្នាន: អឺខ្ញុំចង់សួរថា ក្នុងកងរបស់បងហ្នឹង កងចល័តហ្នឹងស្របាលណាដែរ?

គា: ស្របាលប្រហែលពីអាយុ១២ឆ្នាំដល់អាយុ២០ឆ្នាំអីហ្នឹងណាស់ ។

ខស្នាន: ហើយកងចល័តហ្នឹងមានដូចថា មានបុរស មាននារីនៅលាយឡំជាមួយគ្នា ឬក៏គេដាក់កងចល័តផ្សេងៗគ្នា?

គា: មានតែនៅដោយឡែកៗពីគ្នាក្រុមដោយខ្លួន ។

ខស្មានៈ	ក្រុមដោយខ្លួនពីគ្នា?

គាៈ	បុរសផ្សេង នារីផ្សេង ។

ខស្មានៈ	បាទ ចុះធ្វើការទៅធ្វើចូលគ្នាឬក៏ធ្វើការផ្សេងគ្នា?

គាៈ	ធ្វើការជាមួយគ្នា ប៉ុនធ្វើការដោយឡែកៗដែរ ។ ម៉ាក្រុមក្រុមគេធ្វើផ្សេង យើងធ្វើផ្សេងចឹងទៅ ។

ខស្មានៈ	តែធ្វើការងារអីគឺដូចគ្នា?

គាៈ	ធ្វើការដូចគ្នា ។

ខស្មានៈ	ឱ! ។

គាៈ	កាប់ប្រឡាយលើកព្រែក លើកអាងដូចគ្នា ។

ខស្មានៈ	បាទ ចុះកងចល័តហ្នឹងគឺធ្វើការយ៉ាងម៉េចខ្លះ ធ្វើការនៅកន្លែងណាខ្លះគេឲ្យធ្វើការ?

គាៈ	ធ្វើការនៅផ្លូង ប្រសូត្រ ទោច ចន្ទ្រា ។

ខស្មានៈ	អញ្ចឹងអត់មានទីតាំងដែលថាច្បាស់នាភូមិណា ឬឃុំណាទេ?

គាៈ	បាទហើយមួយកន្លែង ទៅមួយកន្លែងទៅ ។

អ្នកជិតខាងៈ	ប្រហែលបីថ្ងៃគេផ្លាស់ បួនថ្ងៃគេផ្លាស់ទៅ ។ មួយអាទិត្យគេផ្លាស់ម្តង ។

ខស្មានៈ	អញ្ចឹងអ្នូបង?

គាៈ	បាទ ។

ខស្មានៈ	អញ្ចឹងនៅពេលដែលផ្លាស់ទៅកន្លែងណាម្តងៗ ការរស់នៅអីយ៉ាងម៉េចទៅពេលដែលដែលយប់ប្រលប់អី មកដល់ ។

គាៈ	គេមានកន្លែងគេនៅនោះប្រាប់ស្រាប់ ។

អ្នកជិតខាងៈ	គេដេកទម្លាក់ខ្លួនក្បាលអាអ្លែងទៅណាៗចេះតែដេកទៅ ។

ខស្មានៈ	គេមានកន្លែងគេឲ្យនៅស្រាប់?

គាៈ	បាទមានកន្លែងឲ្យនៅស្រាប់ ។

អ្នកជិតខាងៈ	មានរោងសែងណាពូ ។ បើតូបមានតែដំបូលទេ ជញ្ជាំងអត់មានទេ ចេះតែនាំគ្នាសែងទៅណា សែងទៅ ដូះទៅដល់ភូមិណាភូមិនោះចេះតែសែងទៅ ។

ខស្មានៈ	បាទ ។

គាៈ	ដូះក្នុងភូមិដូចថាបណ្តោយបួនមែត្រ
ទទឹងបីមែត្រទៅវាមានមួនដប់ខ្នងម្តៃខ្នងចឹងទៅណាតាមក្រុមៗទៅ ។

ខស្មានៈ ចុះអឺមកលេងជាមួយឪពុកម្ដាយបានទៅពេលហ្នឹងអញ្ចឹង?

ដល់ឪពុកម្ដាយនៅផ្ទះអាចមកលេងជាមួយ គាត់បានទេ?

គាៈ មកជួបមួយភ្លែតៗបាន ។

ខស្មានៈ មកជួបមួយភ្លែតបាន មកជួប មកសុំគេមកឬក៏យ៉ាងម៉េច?

គាៈ សុំគេមក ។

ខស្មានៈ សុំគេមក?

គាៈ បានមួយម៉ោងអីហ្នឹង ។ អើសុំបានជួនណាសុំបានមួយយប់ទៅណាស់ ។ ខ្លះចឹងបាន តែមួយម៉ោងទេ ។ ហើយម្យ៉ាងទៅដល់ពេលមួយអាទិត្យក្នុងពេលដល់ថ្ងៃសម្រាកហ្នឹង ម៉ែឪគេលែង ។

ខស្មានៈ ឱ!

គាៈ បានអាហ្នឹងបើនៅជិតៗហ្នឹងណា ។

ខស្មានៈ ឪ អញ្ចឹងគេឲ្យសម្រាករាល់ថ្ងៃអាទិត្យ?

អ្នកជិតខាងៈ ថ្ងៃអាទិត្យសម្រាក់បានតែមនុស្សស្រីគេមានរដូវតើ គេឲ្យសម្រាកធ្វើអាចម៍ គេឲ្យលុញ អាចម៍ អើឲ្យលុញអាចម៍ហាលតាមស្រែៗ ។ ការងារស្រាល មិនឲ្យទៅលើដីទេ ។ ខ្ញុំធ្លាប់នៅកងចល័តដែរ ខ្ញុំមិនដឹង ។ គេឲ្យលុញអាចម៍ គេឲ្យលុញអាចម៍ ហើយទៅតាមស្រែគេចូកដាក់ ហើយយកមកបុកត្បាលធ្វើ ។

ខស្មានៈ កងចល័តខាងនារី?

អ្នកជិតខាងៈ ខាងនារី ខ្ញុំដឹងដែរ ។

ខស្មានៈ នៅពេលណាដែលគេឲ្យសម្រាក?

អ្នកជិតខាងៈ នៅពេលដល់ថ្ងៃយើងនៅដើរ ។

គេឲ្យយើងសម្រាកមួយខែគេឲ្យសម្រាកថ្ងៃហ្នឹងអ្នកធ្វើការ ។ ពីរថ្ងៃបើគេ តាមដានយើង ទៀត បើរដូវដើរបានបីថ្ងៃ គេឲ្យបីថ្ងៃបើរដូវបានតែមួយថ្ងៃគេឲ្យទៅទៀត គេអត់ឲ្យនៅទេ គេឲ្យទៅរែកដីទៀត យើងនៅយើងគ្រាន់តែលុញដីអាចម៍ ហ្នឹងវាធូរបន្តិច វាពងស្រាល ។

ខស្មានៈ បាទ ។

អ្នកជិតខាងៈ ចាស៎ ប៉ុន្តែដូចថាចូកពីបន្ទន់មកចឹងយើងដាក់លាយដីដំបូក ដើមទ្រាំងខែត្រ ចេះតែញ៉ុកញ៉ីរចឹងទៅ ។ យើងហាលផ្ទាំងៗ ៗ ។ អើតាមៗខ្សែហាលក្ដៅ ។

ខស្មានៈ ឱគេឲ្យធ្វើកិច្ចការហ្នឹង?

អ្នកជិតខាងៈ ចាស៎គេឲ្យធ្វើកិច្ចការ ។

ខស្មានៈ អញ្ចឹងពេលដែលឈប់មកអត់ឈប់ត្រូវជុំគ្នាដូចថាថ្ងៃនេះគេឲ្យឈប់

ថ្ងៃនេះគេឲ្យឈប់ទេអញ្ចឹង?

អ្នកជិតខាងៈ អត់ចឹងទេ ។

ខស្មានៈ អត់ចឹងទេ?

អ្នកជិតខាងៈ អត់អញ្ចឹងទេ ។

តាៈ ស្រុកនេះបានច្រើនដែរប៉ុន្មានឈ្មោះតែមួយ នៅកន្លែងហ្នឹង ។

ខស្មានៈ ចុះខាងកងចល័តបុរសវិញគេឲ្យឈប់ពេលណាបងនឹកមើលមើ អត់មានឈប់ទេ?

តាៈ ឈប់តែពេលឈឺ ។

ខស្មានៈ ឈប់តែពេលឈឺទេ?

តាៈ ពេលឈឺទៅគេឲ្យឈប់ទៅ ។

ខស្មានៈ ពេលឈឺឲ្យគេឈប់ហើយអីឲ្យឈប់សម្រាកនៅដោយខ្លួនឯងឬក៏គេបញ្ជូនទៅពេទ្យនេះ ពេទ្យនោះដែរ?

តាៈ ឈឺខ្លាំងឲ្យទៅពេទ្យ បើឈឺធម្មតាឲ្យនៅឲ្យសម្រាកនៅកន្លែង ។

ខស្មានៈ ឱ! អញ្ចឹងមានពេលណាបើមកលែងជាមួយ លេងជាមួយឪពុកម្ដាយ នៅផ្ទះ?

តាៈ គ្មានពេលទេ ។

អកជិតខាងៈ គ្មានពេលអីថ្ងៃសម្រាកមួយម៉ោង១ គេសម្រាកមួយម៉ោងហើយ តើពូម៉ោងពីរ ដណ្ដប់ណា៎ ។

តាៈ វាយ៉ាប់ដល់ពេលដល់ឈឺ វាដល់ឈឺបាយមួយកំប៉ុងមាន៦នាក់ ។ អើ! អង្ករមួយ កំប៉ុងហ្នឹង ហើយ៦នាក់ ។

ខស្មានៈ ឪ! ចុះបើអត់ឈឺ?

តាៈ អត់ឈឺទាល់តែពីរនាក់បីនាក់ ។

អ្នកជិតខាងៈ គេឲ្យមាវែកកាឡូងយើងណា ។

ខស្មានៈ ពីរនាក់យ៉ាងម៉េច? មួយកំប៉ុងពីរនាក់?

តាៈ មួយកំប៉ុងពីរនាក់ អ្នកធ្វើការបានណាស់ ។

ខស្មានៈ ឪ!ចុះដល់ពេលឈឺ?

គា: ពេលឈឺមួយកំប៉ុន៦នាក់ ។

ខស្មានៈ មួយកំប៉ុន៦នាក់?

គា: បាទ ។

ខស្មានៈ អញ្ចឹងអ្នកឈឺដែលហូបអត់គ្រប់គ្រាន់កាន់តែឈឺទៅទៀតហើយអញ្ចឹង?

គា: បាទ ។ ម្ល៉ោះហើយធ្វើកុំឲ្យឈឺឲ្យជាទៅវិញ ។

ខស្មានៈ ឪ! ធ្វើកុំឲ្យថា មានអ្នកថាឈឺ?

គា: បាទ ។

ខស្មានៈ អញ្ចឹងពេលហ្នឹងដូចថា គេហៅសីលធម៌បុរសនឹងនារីអីយ៉ាងម៉េចដែរ បងដឹងយ៉ាងម៉េចដែររឿងហ្នឹង?

គា: អត់បានទេ ។

ខស្មានៈ អត់បានយ៉ាងម៉េច?

គា: អត់ឲ្យប៉ះទេ ។

ខស្មានៈ ចុះមានអ្នកណាដែលលួចស្រលាញ់គ្នាទេ នៅក្នុងសម័យហ្នឹងមានដែរនៅក្នុងកងរបស់បង?

អ្នជិតខាងៈ លួចស្រលាញ់ពិតជាលួចស្រលាញ់មែន ប៉ុន្តែអត់ហានទេអត់ហានប្រព្រឹត្តដាច់ខាត ។ ទោះជាលួច ស្រលាញ់យ៉ាងណាក៏ដោយក៏មិនហានប្រព្រឹត្តដែរ ។ បើយើងទៅស្នើប្រធានចឹងទៅ ។

ខស្មានៈ ចុះគ្រាន់?

គា: មិនមែនទេឲ្យស្រលាញ់តើ ឲ្យស្រលាញ់គេការឲ្យដែរតើ ។

អ្នកជិតខាងៈ អើគេស្រលាញ់ៗបានតែស្នើរណាយើងមិនហានលូកឡូំគ្នា...ចឹងទេ ។

គា: អើតាមច្បាប់គេ ។

ខស្មានៈ អញ្ចឹង, នៅពេលដែលស្នើរឧបមាថាយើងស្រលាញ់អ្នកណាដែលស្រលាញ់គ្នាជាមួយអ្នកណាអញ្ចឹង យើងអាចទៅស្នើបានដែរ?

អ្នកជិតខាងៈ ស្នើរបាន, ព្រោះថាគ្រប់ភូមិក៏ការបានដែរអុះ ។ ទាល់តែឡើង៤០គូរហើយទៅ២០គូរ៣០, ៤០, ៥០ឲ្យការម្តង ។ ១០០គូរក៏មានដែរ ។ មិនមែនឲ្យស្នើភ្លាមហើយស្អែកគិតគូរតែមួយគូរអត់បានទេ ។

គា: ទាល់ផុតរដូវធ្វើការ ។

អ្នកជិតខាង: ទាល់តែដុតរដូវធ្វើការទៀតណា ។

គា: បាទ, ឧទាហរណ៍ថាឥឡូវហ្នឹងត្រូវជីកប្រឡាយហើយជីកប្រឡាយចប់ ទាល់តែយើងប្រុងរំសាយមកធ្វើ សហករណ៍តាមផ្ទះហ្នឹង ហ្នឹងការរគ្រឹបហ្នង ។

អ្នកជិតខាង: ការហើយ ជួបគ្នាហើយ ។

គា: តែការបានច្រើនទៅមិនសូវរំសាយទេដល់មកសរុបៗបញ្ជូនទៅស្រុកលិចនោះ ។ សែសិប សាមសិប អីចឹងបញ្ជូនទៅ ។

អ្នកជិតខាង: អ្នកណាបានដើងបញ្ជូនទៅលិចណា ។

ខស្នាន: ការបាន

អ្នកជិតខាង: ការបានគូរៗៗៗអញ្ចឹងមួយដើងមានទាំងគូរៗដង្ហែរទៅលិច បញ្ជូនទៅលិចហ្នឹងណា ។

ខស្នាន: ទៅលិចទៅណាទៅ?

អ្នកជិតខាង: ទៅគេហៅទៅស្រុកស្អីស្រុក?

គា: បញ្ជូនទៅលិចមិនដឹងទៅណា ។

អ្នកជិតខាង: ម៉ាឡៃអីគេនោះ ។ ដឹងស្អីឯណាៗផង ។ ទៅម៉ាឡៃ ។ គេថាស្រុកម៉ោង ។ ម៉ែខ្ញុំគេថា ។ និយាយ ល្អើនៗ ។

ខស្នាន: ហើយគេគេថាបញ្ជូនទៅណា គេបញ្ជូនទៅធ្វើអី?

អ្នកជិតខាង: គេថាទៅឲ្យយើងទៅ ពោធិ៍សាត់ បាត់ដំបងមានល្មុត មង្ស៊ុត សេដា វាថាអញ្ចឹងស្រុកម៉ោងពូកែបុិនៗ ធាក់ អើហើយយើងវាមិនងាប់ហើយចុះយើងបាយ ប៉ុណ្ណឹងៗ បើមិនសម្បូរផ្លែនៅផ្សារទាំងកានរៗ ។ ផ្លែប៉ុនៗមនុស្ស ។ ភ្លាមបើមិនទៅយ៉ាងម៉េចទៅដូងថ្ងៃនោះ ។ ខ្ញុំទៅដល់ត្រឹមម្រាមខ្ញុំរត់មវិញ ។

ខស្នាន: ចុះបងការសម័យនោះ?

អ្នកជិតខាង: ការសម័យនោះដែរ ការជាមួយគាត់ហ្នឹងអ្ហែ ។

ខស្នាន: ការដែលគេចង្អុលឲ្យការឬការដោយការស្ម័គ្រចិត្ត?

អ្នកជិតខាង: ការដោយការស្ម័គ្រចិត្ត ។

ខស្នាន: ស្ម័គ្រចិត្តទេ?

អ្នកជិតខាង: ស្ម័គ្រចិត្ត ។

ខស្នាន: ចុះបងទៅដល់ណាអញ្ចឹង?

អ្នកជិតខាង: ខ្ញុំទៅដល់ម្រាមខ្ញុំត្រឡប់មកវិញហើយខ្ញុំថាបែបប្រធានមិនសួរសោះ ។

ខស្មានៈ ដល់ណា?

អ្នកជិតខាងៈ ដល់ម្រាមអាងយើង អាម្រាមស្វាត់ព្រៃក្រោកហ្នឹង ។ ខ្ញុំចុះដើរតាមជ្រលងក្រោកកណ្ដាលអាធ្រាតមក រកផ្ទះយើងវិញណា ។

គាៈ ដល់អ្នកលឿងបើទៅ បើទៅដល់អ្នកលឿង ។

អ្នកជិតខាងៈ បើទៅ, ទៅដល់អ្នកលឿងហើយប្រជុំគេគៀងប្រមូលរហូត ប៉ុនខ្ញុំគេចណា ខ្ញុំថាបែបមិន ។

ខស្មានៈ គេឲ្យដើរទៅបុក៏មានឡាន?

អ្នកជិតខាងៈ គេឲ្យដើរតាមដំណើរបន្តិចៗៗទៅ ។ ត្រូវតែទៅ ។

ខស្មានៈ គេមានសំបុត្រឲ្យទេពេលដើរ?

អ្នកជិតខាងៈ គេគ្មានសំបុត្រទេ ចេះតែកេគៀទៅ ។

ខស្មានៈ អត់មានទេ?

អ្នកជិតខាងៈ អើយើងហើយគេបញ្ជូនបន្តរដូចថាប្រធានភូមិហ្នឹងដាក់ភូមិហ្នឹង ភូមិគេឡើងតទៅទៀត ។ ហើយយើងអាចុងភូមិមកផ្ទះយើងណោះវិញ ។ ឲ្យភូមិជុតភូមិហ្នឹងគេតទៅទៀតមួយទៀត ។

ខស្មានៈ ហើយបងគេចមក ។

អ្នកជិតខាងៈ ខ្ញុំលួចគេចមក ។ គេមិនចំណាំទៀតទេ ។ តាមពិតគេមិនចំណាំទេ ខ្ញុំចុះតាមក្រោកស្វាត់ឈើងមក ។

ខស្មានៈ តែពីរនាក់ហ្នឹង?

អ្នកជិតខាងៈ គាត់ដើរផ្លូវផ្សេង ខ្ញុំដើរផ្លូវផ្សេង ។ កុំឲ្យជួបគ្នា ។

ខស្មានៈ អញ្ចឹង?

គាៈ ដល់មួយគ្រួសារទាំងឪទាំងម៉ែក្មេកទាំងអស់ហ្នឹង ។ មួយសហករណ៍មក?

ខស្មានៈ មួយសហករណ៍យ៉ាងម៉េច?

គាៈ អើ, ចេះតែវៀតមកមួយសហករណ៍យើងដែលគេឲ្យទៅ ទៅមួយសហករណ៍យើងមក ប្រហែលមួយក្រុមរបស់គ្នាយើងចឹងមក ។

ខស្មានៈ អញ្ចឹងបង គឺថាទៅមិនមែនទៅតែអ្នកការទេទៅអ្នកដែលចាស់ទំអីទៅទាំងអស់ដែរ?

អ្នកជិតខាងៈ ទៅទាំងអស់ ទៅទាំងឃុំៗ ប៉ុនអាអ្នកការៗគ្នាពិបាកណាដូចថាមិនបានដេកមិនបាន នៅចេះតែបញ្ជូនគ្នា ទៅៗណា ។

គា៖ ទេអ្នកមុនទេ អ្នកមុនទេ ឬអ្នកការៗទៅហ្នឹងនោះ ។

ឧស្មាន៖ ឱអ្នកមុនទេ?

គា៖ បានខ្ញុំនិយាយមិញច្រឡំហើយ ច្រឡំដែលខ្ញុំរត់ទៅវាអស់សហករណ៍ហើយ ។

ឧស្មាន៖ ចុះនៅពេលគេបញ្ជូនបងគឺបញ្ជូនទាំក្រុមគ្រួសារដែរហ៎?

គា៖ បាទ ។

ឧស្មាន៖ ដឹងថាមូលហេតុបានជាគេបញ្ជូនក្រុមគ្រួសារទៅចឹង បញ្ជូនប្រជាជនពីហ្នឹងទៅកាលនោះ?

គា៖ អើគេថាបញ្ជូនឲ្យខ្មែរយើងទៅនៅឯណោះគេយកចិនមកដាក់ម្ដង ខ្ញុំក៏មិនបានដឹងដែរណា ។

ឧស្មាន៖ ឬអ្នកណាប្រាប់?

គា៖ ពុតែអង្គការថា ។

អ្នកជិតខាង៖ សហករណ៍ហើយឃុំគេ កាលហ្នឹងណា ។

ឧស្មាន៖ ពុពីណា ពុប្រធានសហករណ៍ឬក៏ពុពីណាដែលនិយាយអញ្ចឹង?

គា៖ ប្រធានសហករណ៍ ។

ឧស្មាន៖ គេថាយ៉ាងម៉េច?

គា៖ គេថាឲ្យយើងទៅនៅហ្នឹងគេទុកចិនមកនៅស្រុកហ្នឹងម្ដង ។

ឧស្មាន៖

អ្នកជិតខាង៖ ផ្លាស់ដីគ្នា ។ ហើយម្ខោះហើយទៅមែនៗ ទៅផ្លាស់ ហើយមិនបាច់បញ្ជូនហើយ សុំទៅទៀតហ្ន៎ ។ អឺមានសុំទៅទៀត ។ សុំថែមទៅទៀត ។

ឧស្មាន៖ ចុះអឺ នៅពេលហ្នឹងមានអ្នកភូមិហ្នឹងដែលអត់ទៅចឹងដែរ មានទេ?

អ្នកជិតខាង៖ មាន ពីរនាក់អត់ទៅដែរ ។

ឧស្មាន៖ គេអត់ចុចឈ្មោះឲ្យទៅឬយ៉ាងម៉េច?

អ្នកជិតខាង៖ អត់មានឈ្មោះទេ អត់មានឈ្មោះគេអត់ទៅទេ ។

ឧស្មាន៖ ឱគេមានកត់ឈ្មោះឲ្យទៅ?

អ្នកជិតខាង៖ ចាសគេមានកត់ឈ្មោះឲ្យទៅទាំងម៉ាក្រុមដែលទៅ ។

គា៖ ឆ្លើយមិនបានស្អាតដល់មិនដឹងដឹងខែណា មិនដឹងថ្ងៃណា មិនដឹងឆ្នាំណា ។

ខស្នាន: អត់អីទេបង អឺអញ្ចឹងបងមើលឃើញថាអ្នកដែលគេឲ្យទៅហ្នឹង អ្នកដែលគេកត់ ឈ្មោះឲ្យទៅ ហើយអ្នកដែលគេអត់មានឈ្មោះឲ្យទៅហ្នឹង ខុសគ្នាយ៉ាងម៉េចទៅ?

អ្នកជិតខាង: ខុសគ្នាទាំងអស់ ។

ខស្នាន: បាទ ខុសគ្នាយ៉ាងម៉េចទៅ ហេតុអីបានអ្នកនេះគេឲ្យទៅអ្នកនោះគេឲ្យនៅវាខុសគ្នាយ៉ាងម៉េចទៅ, ប្រជាជន?

អ្នកជិតខាង: អើទៅអស់រលីងហ្នឹង ។ នៅបួនដប់គ្រួសារដែរនៅ ។

ខស្នាន: នៅទេអ្ហ៎?

អ្នកជិតខាង: ច្រើនជាង ។

ខស្នាន: ឱ!

គា: វាមិនទាន់ដល់ថ្ងៃគេហៅ ។

អ្នកជិតខាង: គេថាដែរ គេថាអ្នកភូមិគេថា អ្នកទៅមុនទៅសិនចាំបន្តិចខ្ញុំទៅក្រោយដែលអ្នកភូមិប្រធានសហករណ៍ គេហ្នឹង ។ គេថាឥឡូវអ្នកហ្នឹងផ្លាស់ទៅមុនសិនចាំបន្តិចចាំមកយកអ្នកក្រោយទៅទៀត គេថាអញ្ចឹង ។ គេថាយកទាំងអស់មុនហើយនិងក្រោយ ។ ហើយដល់ហើយអញ្ចឹងហើយបើអ្នកក្រោយឆ្លងមិនទាន់ ទំលាក់ទៅលើអ្នកលឿងហើយ ។ បើគ្មានទូកក៏ទម្លាក់ហើយទៅ ទៅចុងក្រោយហ្នឹង ។ ខ្ញុំស្តាប់ពុអញ្ចឹងទៅ ខ្ញុំខ្លាច ។

ខស្នាន: អញ្ចឹងពេលដែលបងត្រឡប់មកវិញហ្នឹង នៅភូមិ, ឃុំនោះគេមិនដឹង គេមិនដឹងថាបងត្រឡប់មកវិញ?

អ្នកជិតខាង: មកត្រឡប់មកវិញគេដឹងប៉ុនគេមិនបើកបាយឲ្យយើងស៊ីទៀតទេ គេឲ្យយើងទៅហើយនោះ ។ ប៉ុនយើងចេះតែនៅត្រដាប់ត្រដួសតាមដំណើរទៅ ម៉ែ ម៉ែឪយើងច្បិចមកបន្តិចទៅ ។ គាត់ទៅបើកបាយមួយចាន គាត់ច្បិចមកឲ្យទៅ ។

ខស្នាន: ចុះម៉ែឪអត់ទៅ?

អ្នកជិតខាង ម៉ែឪអត់ទៅទេ នៅម៉ែឪខាងខ្ញុំ ម៉ែឪគាត់ខូចអស់ហើយ ។ ហើយដល់ម៉ែឪខាងខ្ញុំគាត់ច្បិចឲ្យមួយមាត់ មួយមាត់ទៅរស់ទៅ ។ គេមិនឲ្យយើងនៅទេ ព្រោះឈ្មោះទៅហើយមានបាយណារបបណាបើកឲ្យយើង ស៊ីទៀតទេ ។

ខស្នាន: បាទ បងពេលទៅហ្នឹងពេលដែលពួកខាងនារតីមកហ៎ ពេលដែលគេបញ្ជូនទៅហ្នឹង?

អ្នកជិតខាង: ហ្នឹងហើយ ពួកនារតីមកហ្នឹងហើយ ។ ពួកវាល្អើនៗណា ពួកវាមិនសូវធំទេ ។

ខស្មានៈ ពួកនោះតូចៗទេ?

អ្នកជិតខាងៈ តូចៗមិនធំទេ តូចល្អិតៗ ។

ខស្មានៈ ហើយពេលហ្នឹងបងឃើញមានការផ្លាស់ប្តូរអ្នកដឹកនាំទេ ដូចប្រធានកង ប្រធានសហករណ៍ ប្រធានឃុំ ស្រុកអីមានផ្លាស់ប្តូរទេ?

អ្នកជិតខាងៈ ផ្លាស់ប្តូរគ្នាដែរ ទាំងអស់តែគ្នាហ្នឹង ។

ខស្មានៈ មានការផ្លាស់ប្តូរដែរ?

អ្នកជិតខាងៈ ការផ្លាស់ប្តូរដែរ ចល័តចុះចល័តឡើងឃើញគេមកចល័តម្តងៗណា ។ ពួកមកពីហ្នឹងមកពីមុខមកម្តងៗណា ។ ស្រាប់តែមកខ្ទិចខ្ទុចៗចឹងចុះឡើងៗ គេសម្គាល់ចឹងទៅថាមានផ្លាស់ចឹងទៅ ។ ចាស៎ ហើយប៉ុនស្រុកមកពីនោះតូចៗទេ គ្មានធំទេ ។ ហ្នឹងគេធ្វើការ អ្នកដែលធ្វើការដែរគេធ្វើការជាមួយអង្គការឃុំ ប្រធានឃុំ ប្រធានសហករណ៍ច្របូកច្របល់គ្នា ។ គេមិនឲ្យយើងរាស្ត្រដឹងការចាំបាច់អីទេ គេដឹងតែបញ្ជូនទៅចឹងណា ។

ខស្មានៈ អីអញ្ចឹងខ្ញុំចង់ដឹងកន្លែងនេះបន្ថែមបន្តិចទៀតបង កន្លែងដែលគេឲ្យរៀបការជាមួយគ្នាហ្នឹង តើមានដូចករណីគេឲ្យការអ្នកដែលអត់ស្គាល់គ្នាឬក៏អត់បានស្រឡាញ់គ្នាមុនហើយគេចាប់ឲ្យការមានទេ?

អ្នកជិតខាងៈ ទេមានតែអ្នកដែលការហើយដែល ។

គាៈ ទាល់តែយើងស្ម័គ្រចិត្តដែរបិនគេការឲ្យ ។

អ្នកជិតខាងៈ អ្នកការហើយចេះតែបែកគ្នាមានច្រើនៗ ហើយបើពីធីរៀបការហ្នឹង ការ៥០គូ ៦០គូគ្នាគេចាប់ការគ្នា មានដាក់ថ្មីមៗហើយគេឡើងប្តេជ្ញាទៅអ្នកណា ។

ខស្មានៈ បងនិយាយមិញថាអ្នកណាចង់ការទាល់តែទៅស្នើរគេ?

អ្នកជិតខាងៈ អើ, ទៅស្នើរគេតែអ្នដែលនេះគេចូលមកដែរព្រោះគេថាអ្នកចងការចឹង គេរំសាយថាឲ្យនៅតាមសហករណ៍, ម្ល៉ោះហើយចង់ការហ្នឹងគេដែរ ។ ដល់ហើយ ចង់ការហ្នឹងគេដែរចឹង ការហើយចឹងគេមានឲ្យនៅតាមសហរណ៍ គេបញ្ជូនទៅទៀត ។ ម្ល៉ោះហើយវាត្រូវធ្វើបែកគ្នាចេះអ្ហែ ។ ធ្វើសមត្ថភាពចេះដែរអ្ហ៎ ។

ខស្មានៈ ចុះដល់អ្នកដែលមិនចងការហើយគេឲ្យការមានដែរ?

អ្នកជិតខាងៈ គ្មានទេ ។

ខស្មានៈ អត់មានទេ?

អ្នកជិតខាងៈ ចង់ការ ចង់ការចឹង ហើយចេះតែចង់ការចេះតែស្រឡាញ់គ្នាជាគូជាគូចឹងទៅថា ឲ្យតែអ្នកមេៗគេ គេថា បែករៀងៗខ្លួននៅតាមសហករណ៍ ។ ដើររើកអន្ទាមចាស់ជាជាការស្រោល ។ ម្ញោះហើយចេះតែការការ ដល់ហើយគេមានការ ហើយគេមានឲ្យការចឹងទេ គេបញ្ជូនហើយ ។

ខស្មានៈ បាទ, អញ្ចឹងអឺ ដូចអ្នកភូមិនេះអីអ្នកដែលបានរៀបការសម័យខ្មែរក្រហមច្រើនដែរអ្ហ៎?

អ្នកជិតខាងៈ ច្រើនដែរប៉ុនពិបានស្មាន ។ ស្លាប់អស់ហើយ ។

ខស្មានៈ ឪស្លាប់អ្ហ៎?

អ្នកជិតខាងៈ ចាស៎ ស្លាប់អស់ហើយពូ ។ គ្មានទេ នៅភូមិពីរនាក់ ។

ខស្មានៈ អឺនៅពេលការគេរៀបចំពិធីយ៉ាម៉េចខ្លះទៅ?

អកជិតខាងៈ ទឹកតែ ទឹកតែយើង ហ្នឹងគេដាំមតែមានតែ ប៉ុនគេដាំទឹកក្តៅណា៎ ។ អើគេឡើងហូបណា៎ ហើយមានបាយ មានសម្លរអីគេឲ្យអន្លុយហើយគេដាក់ភ្លើងមាំងសុងទៅ ។

ខស្មានៈ យប់ហ៎?

អ្នកជិតខាងៈ ចាស់យប់ ។

ខស្មានៈ គេធ្វើយ៉ាងម៉េច?

អ្នកជិតខាងៈ គេឲ្យឡើងប្តេជ្ញាថាខ្ញុំសុខចិត្តប្តេជ្ញាពិតយកប្តីខ្ញុំអស់មួយជីវិតចឹងទៅណា ។ គេឲ្យឡើងណា គេឲ្យឡើង ដូចថាមានពីរបីគ្រួសារចឹងគេឡើងមួយ ។ ដូចថាហ្នឹងប្រធានក្រុមនារីអញ្ចឹងមានបីចឹងឡើងមួយ ឡើងទៅ ឡើងឈរឲ្យខ្ពស់ហេយនិយាយទៅប្តេជ្ញាចិត្តចឹងទៅថា ខ្ញុំប្តេជ្ញាចិត្តយកគ្រួសារខ្ញុំអស់មួយជីវិត ។ មិនចាំបាច់ពិបាកមុខពីបាកក្រោយ ខ្ញុំសុខចិត្តយកចឹងតែម្តង ។ ហើយប្តេជ្ញចិត្តចឹង ។

ខស្មានៈ ឪ! ហើយអ្នកណាដែលមកចូលរួម?

អ្នកជិតខាងៈ មកចូលរួមតែប្រធានឃុំ ប្រធានកងចល័តគេ មេគេមេរាវៗ ។ មេរាវៗ គេដូចថាដឹកនាំយើង ដូចថាស្រី ចឹងមានប្រធាននារីស្រី ពួកប្រុសចឹងមានប្រធានគេប្រុស ។ គេមកបួតគ្នាសរុបគ្នាចឹងណា ។ ចាស៎រួមគ្នា ធ្វើអញ្ចឹង ។

ខស្មានៈ អញ្ចឹងអត់បានឡើងប្តេជ្ញាគ្រប់គ្នាទេ?

អ្នកជិតខាងៈ អត់បានប្តេជ្ញាគ្រប់គ្នទេព្រោះក្នុងមួយការ ៥០គូប្តេជ្ញាតែបីនាក់ បួននាក់ទេ ។

ខស្មានៈ ឪ! អឺ ចឹងគ្រាន់តែប្តេជ្ញាចឹងហើយចប់ហើយពិធីហ្នឹងអ្ហ៎?

អ្នកជិតខាង: គេឲ្យអង្គុយវិញ ។

ខស្នាន: គេឲ្យអង្គុយវិញ?

អ្នកជិតខាង: ចាស៎គេឲ្យអង្គុយគុហ្នឹងគេមិនទាន់ឲ្យចេញទេ គេនៅសម្រួលយើងហ្នឹងឲ្យបានស្អាត គេនៅនិយាយ សម្រួលយើងថាកុំឲ្យមានចេះចុះអីទឹងគ្នា ទាស់ទែងអីគ្នាចឹងណា៎ គេចេះតែអប់រំយើងណាឲ្យខំធ្វើការជួយ ជួយអង្គការសមភាព ក្នុងការងារ ក្នុងកងចល័ត យើងនោះឲ្យមានកំលាំពលាំង ឲ្យសាមគ្គីរឲ្យកាន់តែមុតឡើង កុំឲ្យមានចេះចុះគ្រួសារ ។ មានស៊ីមានអាកអន់ចិត្តអីឲ្យស្រុះដៃគ្នាប្រឹងឡើង ក្រោកឈរឡើងណាគេថាចឹងដែរ ។ អើគេថាចឹងដែរ ។ អើកុំមានការហើយអូអាងពំនឹងពឹងផ្អែកទៅលើប្តទៅលើប្រពន្ធអីអត់បាទេ ។ គេថាចឹងណា គេថាឲ្យយើងប្រឹងឈរសិទ្ធប៉ុនគ្នាឡើងណា៎ ។ ចាស៎ៗ ។

ខស្នាន: អឺ មានរឿងដែលដូចថាបានរៀបការជាមួយគ្នាហើយ ហើយចង់លែងគ្នាវិញមានទេ?

អ្នកជិតខាង: មានច្រើនដែរ ។

ខស្នាន: មានដែរ?

អ្នកជិតខាង: មាន ។

ខស្នាន: នៅក្នុងពេលហ្នឹងណា?

អ្នកជិតខាង: នៅក្នុងពេលហ្នឹងមាន ។

ខស្នាន: បាទ ចុះគេឲ្យលែងទេតាមច្បាប់គេ?

អ្នកជិតខាង: គេមិនឲ្យលែងទេ គេយកទៅឃុំ គេយកទៅឃុំដាក់បន្ទប់ ។ បើយើងនៅតែរឹងគេយកទៅឃុំក្នុងកន្លែងឃុំ ដូចថាឃុំអង្គការគេធ្វើខាងឃុំនោះ ។ គេយកដាក់បន្ទប់តែមួយចឹងគេតាមដាន យាមយើងឲ្យយើងនៅដេក ហ្នឹងពីរនាក់ហ្នឹង គេយាមយើងគេតាមដានយើងទាល់តែយើងយកគ្នាបានបិនគេឲ្យលែង ។

ខស្នាន: យកគ្នាបានម៉េច?

អ្នកជិតខាង: ទាល់តែយើងអោបគ្នា ស្រឡាញ់យកគ្នាបានណា គេតាមដានម៉ោងគេដឹងទៀតណា៎ ។ ហើយបានស្អែក ខានស្អែកបានគេលែងយើង ។ អើចឹងច្បាស់ណាស់បានគេលែង ។ គេធ្វើបន្ទប់គេមួយ ។ គេឲ្យដេកពីរ នាក់ ។ អើបើយើងមិនចូលយើងអង្គុយទាល់តែដាច់ខ្យល់ហ្នឹងទៅ ។ ទាល់តែយើងព្រមបានសព្វគ្នាបាន គេលែងថាអើបានហើយ ។ គេថាអើបានហើយលែងទៅ ។

ខស្មានៈ ចុះយើង យើងធ្វើលេងៗខបមាថាយើងធ្វើអោបគ្នាលេង?

អ្នកជិតខាងៈ មិនមែនទេ មិនមែន ធ្វើលេងៗបាត់ខ្លួនណាយ៉ាប់កាំភ្លើងពីរដើមនៅពិនិតយើងណាំ ។

ខស្មានៈ គេនៅពិនិត្យយើង?

អ្នកជិតខាងៈ គេនៅពិនិត្យយើងហ្នឹងហើយ ។

គាៈ គេលែងគ្នាគេយកមកផ្សំផ្គុំឲ្យបានជាគូរប្រញ៉ាប់គេយកទៅឲ្យគ្រប់ ឲ្យគ្រប់ផែនការគេ

ខស្មានៈ អញ្ជឹងអត់មានគេអនុញ្ញាតឲ្យលែងគ្នាទេអញ្ជឹង?

អ្នកជិតខាងៈ អត់អនុញ្ញាតឲ្យលែងគ្នាទេ ។

ខស្មានៈ អត់ឲ្យលែងគ្នាទេ?

អ្នកជិតខាងៈ អត់លែងបានទេ ។ គេយកទៅធ្វើទុកឯទ្រុងបាន បានរាងមកស្រុកវិញ ។ ទៅធ្វើ មីទិញទៀតហ្នំ ។

ខស្មានៈ ធ្វើមេទិញយ៉ាងម៉េចទៀត?

អ្នកជិតខាងៈ ធ្វើមេទិញ កាត់ទោសណាំ នៅតែរឹងកាត់ទោសណាំ ។

ខស្មានៈ បើសិននៅតែអត់នៅជាមួយគ្នាទៀតគេធ្វើមេទិញកាត់ទោស?

អ្នកជិតខាងៈ កាត់ទោស ។

ខស្មានៈ កាត់ទោសយ៉ាងម៉េចទៅ?

អ្នកជិតខាងៈ កាត់ទោសគេយកទៅកហាត់ធ្វើការកន្លែងភូមិ ឃុំកន្លែង កន្លែងសន្តិសុខអីចឹង ទៅគេធ្វើការ ធ្វើស្មៅ
ក្រុមគេចាប់គេបញ្ជូរណាំ ។

គាៈ ខទាហរណ៍គេនិយាយយើងមិនបានគេបញ្ជូនយើងទៅទៀត ។

អ្នកជិតខាងៈ ហៅយើងទៅប្រជុំទៀតហ្នំ ។ ដូចថាកាត់ទោសអីចឹងណាំ ។

គាៈ ណែនាំយើងស្តាប់មិនបានគេមានវិធានការណ៍ទៀត ។

ខស្មានៈ មានដែរ មានអ្នកដែលគេកាត់ទោសចឹងដែរហ៎?

អ្នកជិតខាងៈ មានអ្នកបញ្ជូនទៅទៀត គេថាយើងរឹងគេបញ្ជូនទៅទៀត ។

ខស្មានៈ គេបញ្ជូនទៅណា?

អ្នកជិតខាងៈ គេបញ្ជូនទៅក្រោម គេបញ្ជូនទៅកន្លែងឃុំ ឃុំទៅកន្លែងប៉ុស្តិ៍ហើយកន្លែងប៉ុស្តិ៍ ហើយទៅស្វាយសន្ទឹម ។

ខស្មានៈ កន្លែងហ្នឹងធ្វើអីទៅ?

អ្នកជិតខាងៈ គុកស្វាយអន្ទីម ។ គុកស្វាយអន្ទីមណា ។ ដាក់គុក ។

ខស្មានៈ នៅកន្លែងណាគុកហ្នឹង?

អ្នកជិតខាងៈ គុកនៅស្វាយអន្ទីម ។ នៅស្វាយអន្ទីម ។

ខស្មានៈ នៅឈ្មោះស្វាយអន្ទីមនៅកន្លែងណាទៅ ស្រុកអី?

អ្នកជិតខាងៈ គេហៅស្រុកស្វាយអន្ទីមហ្នឹង? ស្រុកស្វាយអន្ទីមចឹងតែហ្នឹង ។ ស្វាយអន្ទីម ។

ខស្មានៈ នៅខេត្តស្វាយរៀងហ្នឹងដែរ?

អ្នកជិតខាងៈ នៅខេត្តស្វាយរៀងយើងណាំ ។ នៅខេត្តស្វាយរៀងដូចតែគ្នាហ្នឹងពូ ។

ខស្មានៈ បាទ ។ ចុះអី អឺ ពេលដែលត្រូវរៀវគ្នាហើយប្តីប្រពន្ធហ្នឹងនៅផ្ទះជាមួយគ្នាដែរ?

អ្នកជិតខាងៈ ចាស់ គេឲ្យនៅផ្ទះជាមួយគ្នា គេឲ្យយប់ ថ្ងៃបែកគ្នាធ្វើការ ទាល់តែពេលយប់មក ឲ្យរស់នៅជាមួយគ្នា ។

ខស្មានៈ ឪ!ចុះដូចបងប្អូននិយាយដំបូងថាការហើយគេបញ្ជូនយកទៅខាងលិច?

អ្នកជិតខាងៈ អាពួកនោះគេបញ្ជូនគេបញ្ជូនបណ្តើរៗណាំ ។

ខស្មានៈ ឪ! បញ្ជូនបណ្តើរ?

អ្នកជិតខាងៈ បណ្តើរៗៗ ។

ខស្មានៈ អញ្ចឹងដំបូងបង្អស់គឺគេបញ្ជូនអ្នកដែលទើបតែរៀបការ?

អ្នកជិតខាងៈ ហ្នឹងហើយ ។ បញ្ជូនទៅបន្តទៀតទាំងគ្រួសារៗ ។ វាអញ្ចេះ ដំបូងបង្អស់ពួកដែល នៅកន្លែងស្រុកហ្នឹង ទៅមុនហើយ អ្នកដែលត្រូវទៅចេះតែទៅចេះបន្តៗៗគ្នាទៅ ។

ខស្មានៈ អញ្ចឹងពេលដែលគេបញ្ជូនទៅ អឺខាងលិចហ្នឹង អឺដូចថាអ្នកដែលទើបតែការហើយថ្មីៗ ហ្នឹងពេលហ្នឹងពួកល្អិនមកហើយនៅ?

អ្នកជិតខាងៈ នកហើយ ។

ខស្មានៈ មកហើយ?

អ្នកជិតខាងៈ មកចូលដល់ខាងកើតហ្នឹង ។ ពួកល្អិនមកបានការយើង ។ វាមកការយើងហ្នឹង ។

ខស្មានៈ អញ្ចឹង?

គាៈ ការប្រកាសពីភូមិទៅហ្នឹង ។

ខស្មានៈ ចុះបើពួកអាល្អិនហ្នឹងអត់ទាន់មកអត់ទាន់ឲ្យការទេ?

អ្នកជិតខាងៈ អត់ទាន់ការទេ នៅ ។

ខស្មានៈ អត់ការទេ?

គា: ហ្នឹងហើយដូចថាជួនកាលតាមសហករណ៍វិញហើយ ។ មានអីកាលពីម៉ា ពីដើមមុននោះ ។

អ្នកជិតខាង: គេឲ្យការតាមសហ..... ការតាមសហករណ៍ខ្លះ ។ ហើយដល់កន្លែងឃុំនោះបានការនោះ១០គូរ ៥០គូរ ១០០គូរ ។

គា: លើកក្រោយការបញ្ជូន ការបញ្ជូននេះ ។

ខស្មាន: អញ្ចឹងជំបូងការដែរតែការតិចអញ្ចឹង?

អ្នកជិតខាង: ការតិច ។

ខស្មាន: ហើយអត់មានបញ្ជូនទៅលិចទេ?

អ្នកជិតខាង: ការ ការហើយគេ..ពីដើមមកអាល្អឹនមិនទាន់មកយើងការតាមសហករណ៍មួយពីរវាធម្មតាអញ្ចឹងណ៎ ។ ស្រែនៅធ្វើចំការធម្មតាចឹងណ៎ ។ ដល់ពួកហ្នឹងមកគេកាន់តែការច្រើនៗ គេបញ្ជូនទៅពីរៗរបស់គេ ។

ខស្មាន: ចុះជំបូងហ្នឹង, ពិធីរៀបការគេពួកអាល្អឹនមកហើយមុនហ្នឹងពិធីរៀបការគេធ្វើដូចគ្នាអត់ទេ គេរៀបចំដូចគ្នា អត់ទេ?

អ្នកជិតខាង: ដូចតែគ្នា ។

ខស្មាន: ធ្វើដូចគ្នា?

អ្នកជិតខាង: ចាសធ្វើដូចតែគ្នា ។

ខស្មាន: ចុះបងការពេលដែល ពួក ពួកហ្នឹងមក?

អ្នកជិតខាង: ចាស់ខ្ញុំការ៤០គូរ ។

ខស្មាន: ៤០គូរអ្ហ៎?

អ្នកជិតខាង: ចាស់៤០គូរ ។

ខស្មាន: ហើយសព្វថ្ងៃនៅប៉ុន្មានគូរដែលនៅជាមួយគ្នាហ្នឹង?

អ្នកជិតខាង: ស្លាប់អស់ហើយនៅតិចណាស់ ។

ខស្មាន: នៅប៉ុន្មានគូរ ប្រហែលជនៅប៉ុន្មាន?

អ្នកជិតខាង: នៅ, បើស្រុកខ្ញុំឯក្តាមឯណោះទៅទាំងអស់មាក្រុមគ្រួសារ ដេញមាការក្រុមសេសទៅទាំងអស់ ។ នៅខ្ញុំហ្នឹងខ្ញុំ ហ្នឹងបែកមកនេះមួយ ។ ៤៣គូរ

ខស្មាន: ៤៣គូរអ្ហ៎? ៤៣គូរនៅជុំគ្នាទាំងអស់ទេ? នៅជុំគ្នាទាំងអស់ទេឬក្រោយមកបែកគ្នាទៀត?

អ្នកជិតខាង: ខ្ញុំនៅ.....គេនៅឃុំគេឯណោះ ។

ខស្នាន: ប៉ុន្តែនិយាយប្តីរបពន្ធគេមានបែកបាក់គ្នាដែរ?

អ្នកជិតខាង: អត់បែកទេនៅគូររបស់គេ ។

ខស្នាន: នៅជាមួយគ្នាដល់សព្វថ្ងៃហ្នឹង ។

អ្នកជិតខាង: ដល់សព្វថ្ងៃហ្នឹង ។ ខ្លះស្លាប់ទៅ ខ្លះនៅទៅ ។

ខស្នាន: បងខ្ញុំចង់សួរមួយចំណុចទៀត អ៊ីបងដែលឃើញប្រជាជនដែលចេញពីភ្នំពេញមកគេជំលៀសមកដល់ហ្នឹង ទេ?

អ្នកជិខាង: គេជំលៀសមកដល់នេះ ។

ខស្នាន: មានដែរ?

អ្នកជិតខាង: មាន ។

គា: ហ្នឹងគេបញ្ជូនទៅមុនគេ ។

ខស្នាន: អញ្ចឹង, ពួកដែលមកពីភ្នំពេញហ្នឹងធ្វើការនៅកងចល័តជាមួយគ្នា ឬក៏គេដាក់ឲ្យនៅផ្សេងគ្នា?

គា: ជាមួយគ្នា ។ ជាមួយគ្នា ។

អ្នជិតខាង: ជាមួយគ្នាឯហ្នឹង ខាងខ្ញុំ ភូមិខ្ញុំអត់ទេ ។

គា: អញ្ចឹងម៉ាកាលពួកកងចល័តមិនស៊ីឈ្មោះថ្មីដែរ?

ខស្នាន: មានប្រជាជនថ្មីដែរ?

គា: បាទ ។

អ្នកជិតខាង: ប្រជាជនថ្មីគេដាក់លាយចាស់ៗ ។

ខស្នាន: អញ្ចឹងប្រជជនថ្មីអាចមានសិទ្ធការជាមួយរបជាជនបានទេ?

អ្នកជិតខាង: អត់មានទេ ។ អត់ឲ្យប៉ះពាល់ អត់ឲ្យប៉ះពាល់ចូលដើងចឹងទេ ។ ថ្មីហើយនឹងថ្មីដូចគ្នាចាស់ ។

ខស្នាន: ឪអញ្ចឹងការបើប្រជជនថ្មីការបានតែប្រជាជនថ្មីទេ?

អ្នកជិតខាង: ទេអត់ការទេ ។ ការបាន ។ បានតែមួយគូរៗចុងក្រោយ ។

គា: បានតែចុងក្រោយ ។ ការនៅចុងក្រោយ ។

ខស្នាន: ការបានតែជាមួយប្រជាជនថ្មីទេអ្ហ៎?

អ្នកជិតខាង: ថ្មី ថ្មីដូចគ្នា ។ ថ្មីៗដូចគ្នា ។

ខស្មានៈ ចាស់ ចាស់ដូចគ្នា?

អ្នកជិតខាងៈ ដូចគ្នាអញ្ចឹង ចាស់ដូចគ្នា ។

ខស្មានៈ ចុះមានដែលស្រឡាញ់ឆ្លងគ្នាទេ ដូចថាចាស់ស្រឡាញ់អ្នកថ្មី?

អ្នកជិតខាងៈ គេមិនឲ្យយក គេមិនឲ្យយក ។

ខស្មានៈ អត់ឲ្យយក?

អ្នកជិតខាងៈ អត់ឲ្យយកទេ ។

ខស្មានៈ អញ្ចឹងដែលហ៊ានស្រឡាញ់ឆ្លងគ្នាទេ?

អ្នកជិតខាងៈ អត់ហ៊ានទេ ។ ព្រោះអត្នាអត់ហ៊ានមែន ។

ខស្មានៈ អត់ហ៊ាន?

អ្នកជិតខាងៈ អត់ដូចខ្ញុំអញ្ចឹងដែរ ។

ខស្មានៈ កុំអីខ្ញុំមិនការជាមួយគាត់ទេ ការជាមួយគេបាត់ ។

គាៈ ខុសសីលធម៌ ។

អ្នកជិតខាងៈ ដូចច្នេះគេថាអត់បានទេ ។ ថ្មីៗគ្នាគេ ។

ខស្មានៈ ចុះបើមានករណីបើនៅតែស្រឡាញ់គ្នាដូចថាមិនអាចបែកគ្នាបានធ្វើម៉េចទៅអញ្ចឹង មានរឿងហ្នឹងទេ?

អ្នកជិតខាងៗ គ្មានរឿងហ្នឹងទេ ។

ខស្មានៈ អត់មាននរណាហ៊ានទេ?

អ្នកជិតខាងៈ អត់មានអ្នកណាហ៊ានទេ ។

ខស្មានៈ ចុះឃើញចំពោះប្រជាជនថ្មីហើយចាស់ឃើញខុសគ្នាយ៉ាងម៉េច អីមានកន្លែងណាដែលខុសគ្នាទៀតដូចថាតាំងពី អ្នកចាស់ៗអីដែលមករស់នៅ នៅតាមសហករណ៍អី ឬក៏អ្នកដែលនៅកងចល័តក៏ដោយ ឃើញប្រជាជនចាស់ ហើយប្រជាជនថ្មីហ្នឹងខុសគ្នាយ៉ាងម៉េចទៅ គេ?

អ្នកជិតខាងៈ គាត់មិនសូវបានចេញធ្វើការណាំព្រោះមកពីភ្នំពេញណាំ ។ ចាស់គាត់មិនសូវប៉ុនៗ ធ្វើការទេប៉ុនយើងប្រជាជនថ្មី អុះ យើងប្រជាជនចាស់ហ្នឹងក៏ ស្រឡាញ់រាប់អានគាត់ដែរ ។ យើងមិនធ្វើអីកគាត់ទេ ។ យើងមិនខឹង មិនឃុំឃាំងអីទេ យើងប្រជាជនដូចគ្នា តែបើស្អប់ខាងមកពីលើមិនដឹងបើយើងក្នុងឃុំអត់ ម៉ាចេះខឹងគ្នាទេ ។

ខស្នានៈ អត់មានទឹង?

អ្នកជិតខាងៈ អត់ទឹងទេប៉ុនយើងរាប់អានគ្នាដូចបងប្អូនចឹង ។ យើងយល់តែគេ គេអុចអាល បានគេទឹង ។ តែយើងប្រជាជនមកពីនោះគាត់មិនស្ទូវប៉ិន យើងដែលអ្នកប៉ិន យើងជួយ គាត់ពិតដែរហ្នឹង យើងជួយខ្លះដែរ ។ យើងអ្នកប៉ិនឃើញ អ្នកខ្សត់យើងចេះតែជួយទៅ ។ ហាកទៅនេះ ទៅនោះទាំងអស់គ្នា ។ ហើយគាត់រាង វិសវទុសដែរ ព្រោះគាត់នៅភ្នំពេញដែរ គាត់មិនដែលប្រឡូកទេ ។ ហើយយើងនៅ នឹងនេះតែងប្រឡូកយើងចេះតែ ដឹកនាំគាត់ធ្វើ ធ្វើទាំងអស់គ្នា។ ទៅដល់រាយការណ៍ឡើងថា គាត់បានធ្វើបានទាំងអស់ ។ យើងអ្នកចាស់ហ្នឹង យើងជួយដែរ ។ មិនចេះតែថា..មិនមែនស្អប់គាត់ទេ ។

ខស្នានៈ បាទ អញ្ចឹងការងារដែលគេដាក់កំរិតឲ្យធ្វើប៉ុនគ្នាដែរ?

អ្នកជិតខាងៈ ឲ្យធ្វើប៉ុនគ្នា ។

ខស្នានៈ ចុះការហូបចុកខុសគ្នាទេ?

អ្នកជិតខាងៈ ហូបចុកដូចគ្នា ។

ខស្នានៈ ហូបចុកដូចគ្នា?

អ្នកជិតខាងៈ ដូចគ្នា ស្មើរគ្នា ។

ខស្នានៈ ចុះដូចអ្នកដែលនៅតាមសហករណ៍ដូចចាស់ៗ អឺខាងប្រជាជនថ្មីណា៎ នៅពេលដែល មកដល់ភូមិហ្នឹងគេឲ្យ នៅកន្លែងណាទៅបើគ្នាអត់មានផ្ទះផង?

អកជិតខាងៈ ដូចថា ដក់ ដក់ផ្ទះហ្នឹងចេញមួយ ។ ដក់ប្រជាជនចាស់ចឹងចេញបញ្ចូល អ្នកថ្មីមាផ្ទះហ្នឹងទាំងអស់ ។

ខស្នានៈ ទ្វ!

អ្នកជិតខាងៈ ចាស់ ស្រណុកគេតាមដាន ។ ចាស់ស្រណុកគេតាមដាន គេគ្រប់គ្រងធ្វើការ ។

ខស្នានៈ អញ្ចឹងបានន័យថាគេតាមដានជាងប្រជាជនចាស់?

អ្នកជិតខាងៈ ចុះប្រជាជនចាស់គេលែងអីហើយ យើងទើបនឹងមកថ្មីដឹងយើងម៉េច ។ គេនៅតាម ដានមើលយើងប៉ុន គេមិនធ្វើអី ។

ខស្នានៈ តាមដានយ៉ាងម៉េចខ្លះទៅ?

អ្នកជិតខាងៈ តាមដានយើងក្រែងយើងឈឺ ធ្វើការមិនកើត យើងចេះតែទំរន់ណាស់ ។ អើយើងទំរន់យើងធ្លាប់នៅស្រួល ហើយយើងមកដល់ហ្នឹងក្រែង យើងចេះតែជ្រុប

ចេះតែទំរន់នឹកផ្ទះ នឹកកូន នឹកចៅណាស់បែកគ្នាម្ខោះហើយ គេគាមដានថាឲ្យយើងហ្នឹង ឲ្យយើងលះបង់ធ្វើការឲ្យដូចគេចាស់ចឹងទៅអីគេមិនឲ្យបាយស៊ីទៀតនោះ ។ នៅទំរន់ដល់ណាទៀតបើសហករណ៍ចូលតែមួយចឹងហើយ ។

ខស្នាៈ ចុះពេលរោងបាយគេហូបរោងជាមួយគ្នា?

អ្នកជិតខាងៈ រោងជាមួយគ្នា ។

ខស្នាៈ រោងជាមួយគ្នា ។

អ្នកជិតខាងៈ គេដាក់តុរៀបរបស់គេជួរចឹងគេវាយក្តារ ។

ខស្នាៈ ប្រជាជនចាស់នៅម្ខាងថ្មីនៅម្ខាងឬក៏យ៉ាងម៉េច?

អ្នកជិតខាងៈ អើហូបទាំងអស់គ្នាចឹងណា ប្រឡូកប្រឡាក់គ្នាបាន ។ គ្រាន់តែដួងដើងយើងចូលដល់ហើយទាំងចាស់ទាំងថ្មីហ្នឹង ចូលទាំងគូរទាំងអស់គ្នាទៅ ។ ហ្នឹងគេដាក់សម្ល រដើមចេកដើមល្ហុង ។ សម្លរដើមចេកមាភ្នកប៉ុនអត់ហូបមិនដឹង មកពីមិនឈមទៅ ។ ហើយគាត់មិនចេះហូបទេ ។ ហើយយើងចាស់យើង យើងធ្លាប់ហើយ យើងចេះតែហូបឲ្យ តែបានទៅ ។ បើយគាត់ គាត់ជ្រុបគាត់មិនចេះហូបទេ ។ ខ្លះទាល់តែបីបួនប្រាំថ្ងៃទៅ បានហូបបាន ។ ដែលគាត់ធ្លាប់ឆ្ងាញ់ហ្ន ។ អើ ដែលយើងចាស់ យើងចេះតែហូបឲ្យតែបានកំឡាំងធ្វើការ ។

ខស្នាៈ ចុះមានប្រជុំអីខ្លះមក ដូចថាគេហៅប្រជាជនចាស់ គេអត់ឲ្យប្រជាជនថ្មីចូលរួមប្រជុំ ឬក៏គេហៅប្រជាជនថ្មីអត់ឲ្យខាងចាស់ចូលរួមមានអញ្ចឹងទេ?

អ្នកជិតខាងៈ យើញអត់មានអត់មានអញ្ចឹងផង ។

ខស្នាៈ អត់មានទេ?

អ្នកជិតខាងៈ យើញយកមកដាក់ទាំងអស់ យើញយកមកចូលយើងចឹងតែម្តង ។

ខស្នាៈ បាទប្រជុំអី អីគឺជមួយគ្នាទេ?

អ្នកជិតខាងៈ ជាមួយគ្នាអញ្ចឹងតែម្តង ។ ចាស់ក្មេងអីក៏ដោយ គេអត់មានដាក់ផ្សេងៗ ទេ ។

ខស្នាៈ អត់ទេអ្ហ៎?

អ្នកជិតខាងៈ ប៉ុនគ្រាន់ឲ្យដេកផ្ទះមួយហ្នឹង យើងរើប្រជាជនចេញឲ្យគាត់ដេកសម្រាកទាំងអស់គ្នាហ្នឹងទៅ ។ ម៉ុគ្នាគាត់ហ្នឹងទៅ ។ ដល់ពេលធ្វើការចល័តចូលយើង គ្រាកៗទាំងអស់គ្នាចឹងទៅ ។ យើងដឹកនាំគាត់ ។

ខស្នានៈ ចុះ ពេលប្រជាជនថ្មីអញ្ចឹងរស់នៅជាមួយគ្នា រហូតដល់ពេលគេបញ្ជូនទៅខាងលិចហ្នឹងអ្ហ៎?

អ្នកជិតខាងៈ ចាស់ដល់ទៅម៉ោហឹងហ្នឹងទេគេបញ្ជូនអាហ្នឹងមុនគេផង ។

ខស្នានៈ បញ្ជូនប្រជាជនថ្មីហ្នឹងមុនគេ?

អ្នកជិតខាងៈ ហ្នឹងហើយគេបញ្ជូនមុនប្រជាជនចាស់ទៀតហ្ន រុញមុនគេផង ។ គាត់មិនសូវបើតាមគាត់មិនសូវចេះ ណា៎ ។ វាបញ្ជូនគ្មានសល់មួយមកនៅដល់ស្រុកយើងទេ ។

ខស្នានៈ ចុះមានអ្នកណាដែលធ្វើអី ទោសកើតមានទោសអីដែលគេចាប់ឃុំខ្លួនឬក៏ចាប់យកទៅសម្លាប់នៅអ្នកដែលនៅក្នុងភូមិហ្នឹង មានទេ?

អ្នកជិតខាងៈ គេចាប់ប្រជាជនចាស់ក៏គេចាប់ដែរ ។

ខស្នានៈ គេចាប់ដែរ?

អ្នកជិតខាងៈ គេចាប់ប្រជាជនចាស់ជាងថ្មីផង ។

ខស្នានៈ ឪ!

អ្នកជិតខាងៈ គេមានមូលហេតុគេ គេឫសគេគល់គេ ស៊ីៗគេនោះ ។

ខស្នានៈ មូលហេតុអីទៅ?

អ្នកជិតខាងៈ មូលហេតុគេថាជិនាន់នោះគេថាឲ្យបាយពួកស៊ីពួកស៊ីស៊ីនោះគេចាប់ ។

ខស្នានៈ គេចាប់?

អ្នកជិតខាងៈ គេចាប់ គេចាប់ធ្វើទារុណកម្មវាយដាច់ឈាមច្រូចៗ ។

ខស្នានៈ បងដែលបានឃើញផ្ទាល់ភ្នែកទេ?

អ្នកជិតខាងៈ ឃើញផ្ទាល់ភ្នែក គេដក់ក្បាលត្នោតចងមិនទាន់សកបន្ទាផង ។ អាបន្ទាត្នោតយើងហ្នឹងគេសកខ្ទាក់មក ចឹងគេ រឹតភឹបចឹងវាមុតឆ្អឹបៗ ។ អាគេយកទៅមើលឃើញអញ្ចឹងណា៎ ។

ខស្នានៈ បងឃើញគេចាប់ប៉ុន្មាននាក់?

អ្នកជិតខាងៈ បងឃើញ ខ្ញុំឃើញគេចាប់នៅសហករណ៍ខ្ញុំ តា តានៅភូមិនោះផ្លាស់ទៅហ្នឹង ។

ខស្នានៈ ឪ តាអ្ហ៎?

អ្នកជិតខាងៈ ចាស់ ។

ខស្នានៈ ប្រជាជនចាស់ឬថ្មី?

អ្នកជិតខាង៖ ប្រជាជនចាស់ ។

ខស្នាន៖ ឈ្មោះអី?

អ្នកជិតខាង៖ ឈ្មោះតាហ្នឹង ឈ្មោះតាអីទេ តាដេញគេចាប់មុខផ្ទះសហករណ៍ហ្នឹង ។ តាគុយ ។

ខស្នាន៖ តាគុយអ្ហ៎?

អ្នកជិតខាង៖ តាគុយ ។ តាគុយហ្នឹងគេសក់ខ្មាក់ហ្នឹងគេចងឃឹប មុតហ្នង ។ មុតឃឹបហ្នឹងយកទៅហើយ ហើយមាន ទាំងមិនឡើងសាលាស្រុកអីចឹងទេ ។ ឃើញផ្ទាល់ចឹង ហើយខ្ញុំក៏ភ័យ ចេះតែខំធ្វើការញ័រង្វើរដើងឡើង ។

ខស្នាន៖ ចុះបងនៅឯណាបានឃើញគាត់?

អ្នកជិតខាង៖ ខ្ញុំនៅសហករណ៍ហើយខ្ញុំ ភូមិខ្ញុំឯណោះឯត្រចៀកក្តាមណោះ ហើយគេបញ្ជូនពីនេះទៅ ។

ខស្នាន៖ ការហើយនៅពេលហ្នឹង ការហើយនៅ?

អ្នកជិតខាង៖ ការហើយប៉ុនគាត់ទៅ ទៅបរទេសតាហ្នឹង គាត់ទៅជីកស្រូវ ។ ហើយខ្ញុំនៅរ៉ែកដីតាមសហករណ៍ ។

ខស្នាន៖ ហើយតាហ្នឹងនៅកន្លែងណា?

អ្នកជិតខាង៖ ហើយខ្ញុំបើឈឺបានគេបញ្ជូនទៅហ្នឹង បើមិនឈឺគេឲ្យនៅកងចល័តហ្នឹងវិញ ធ្វើការវិញ ។

ខស្នាន៖ បាទ។

អ្នកជិតខាង៖ ហើយតាហ្នឹងគេបញ្ជូនពីហ្នឹងទៅដាក់សហករណ៍ឯណោះ ។ គេបញ្ជូនពីស្រុកទៅ ។

ខស្នាន៖ ធ្វើសហករណ៍ជាមួយគ្នា?

អ្នកជិតខាង៖ ចាស់ ប៉ុនមិនដឹងខុសអីទេថ្ងៃហ្នឹង ថ្ងៃរសៀលស្មើរហ្នឹង ស្រាប់តែសកបន្ទាអីនៅក្នុងអទីមការផាំរហ្នឹង ក៏មានខ្មាំងដែរ ខ្មាំងនៅត្រង់ហ្នឹង ។ ឯ ខ្ញុំក្រលេកមើលខ្មាំងនៅត្រង់ណា ។ ស្រាប់តែហើយក៏ច្រានតាហ្នឹងចង់ពីបទៅ ឳតាហ្នឹងនៅនៅត្រង់ណោះ គេចងហើយ គេចងទៅហើយ ខ្ញុំ ក៏មើលតែប៉ុណ្ណឹងខ្ញុំទៅ ។

ខស្នាន៖ អាយុប៉ុន្មានតាហ្នឹងពេលហ្នឹង?

អ្នកជិតខាង៖ តាហ្នឹងអាយុប៉ុន្មានហើយ?

គា៖ ៧០ដាង ។

ខស្នាន៖ តាពេលនោះគាត់អាយុ៧០អ្ហ៎?

អ្នកជិតខាង៖ ចាស់អាយុ៧០ ហើយ ។

ខស្នាន៖ ហើយចុះប្រពន្ធគាត់នៅទេ?

អ្នកជិតខាង៖ ប្រពន្ធគាត់ទើបនឹងស្លាប់ ។

ខស្នាន៖ ទើបតែនឹងស្លាប់ទេ?

អ្នកជិតខាង៖ ចាស់ ។

ខស្នាន៖ គេអត់មានចាប់ទេ?

អ្នកជិតខាង៖ គេអត់មានចាប់ទេប្រពន្ធ ។

ខស្នាន៖ គេអត់មានចាប់?

អ្នកជិតខាង៖ គេចាប់តែតាហ្នឹងមួយទេ ។

ខស្នាន៖ ពីណាអ្នកចាប់អ្នកដែលទៅចាប់តាហ្នឹង?

អ្នកជិតខាង៖ មិនស្គាល់គេទេគេសុទ្ធតែកាំភ្លើងហើយគេថាសន្តិសុខ ។

ខស្នាន៖ សន្តិសុខណា?

អ្នកជិតខាង៖ ចាស់គេថាសន្តិសុខ សន្តិសុខ មិនដឹងសន្តិសុខស្អីគេទេ ។

ខស្នាន៖ សន្តិសុខមកពីខាងណាដឹងទេ?

អ្នកជិតខាង៖ មកពីខាងស្វាយទីមគេមកយករបស់គេប្រាប់លអញ្ចឹងតែម្តង ។

ខស្នាន៖ អាហ្នឹងសន្តិសុខស្រុក ឬក៏តំបន់ ឬក៏ស្អីបងមានស្តាប់បានទេ?

អ្នកជិតខាង៖ សន្តិសុខ សន្តិសុខតំបន់តាហ្នឹង មិនមែនសន្តិសុខស្រុក សន្តិសុខឃុំគេមកពីនោះណា៎ ។
បើគេថាមាន ឈ្មោះ អាណារាយការណ៍ទៅឲ្យគេចឹង គេមកយកអញ្ចឹងណាស់ ។

ខស្នាន៖ បាទ ។

អ្នកជិតខាង៖ អើបានគេមកយកពីបហ្នឹង គេថាឪមានកាំភ្លើងគេតើ ។

ខស្នាន៖ បាទប៉ុន្មាននាក់?

អ្នកជិខាង៖ បួននាក់ ។

ខស្នាន៖ បួននាក់អ្ហ៎?

អ្នកជិតខាង៖ ចាស់ ។

ខស្នាន៖ អញ្ចឹងពេលដែលមុនដែលចាប់ហ្នឹងគេហៅប្រជុំឬចាប់នៅកន្លែងធ្វើការ?

អ្នកជិតខាង៖ ស្រាប់តែ ស្រាប់តែស្ទាត់ៗមកតែម្តង ។ កំពុងតែធ្វើការ កមពុងតែជាប់ធ្វើការ ។

ខស្នាន៖ កំពុងតែធ្វើការ?

អ្នកជិតខាងៈ អើ អត់មានប្រជុំផង ។

ខស្មានៈ ចុះតាហ្នឹងធ្វើការដែរ៧០ហ្នឹង អាយុ៧០នោះ?

អ្នកជិតខាងៈ ចាស់គាត់ធ្វើការផ្សារអីជាវិញខ្សែអីដូចជា បបោសដី បបោសអីប្រមូលអាចម៍គោ អាចម៍អីដាក់ ។

ខស្មានៈ បាទ ចុះបងធ្វើអីពេលហ្នឹង?

អ្នកជិតខាងៈ ខ្ញុំរែកស្មៅស្រែ ។

ខស្មានៈ នៅជិតគាត់ហ្នឹងដែរ?

អ្នកជិតខាងៈ នៅជិត ហ្នឹងសហករណ៍ចឹងគាត់ឲ្យគេធ្វើ គាត់ធ្វើការសហករណ៍អញ្ចឹង ហើយខ្ញុំទៅរែកដីពីហ្នឹងយកទៅ ដាក់ហ្នឹងដែរ រែកដីអាចម៍គោណា យកមកដាក់ឡូជាមួយកន្ទ្រាំងខែតហ្នឹងដែរ ។ ចាស់មកដល់ហើយឃើញគាត់ហ្នឹង បើសិនរែកហួសក៏មិនឃើញ ប៉ុន្តែមកដល់ជួនគាត់មកដែរគេចុះមក ។ គេចុះមក គេមកពីត្បូងហ្នឹងដែរចងគាត់ទៅ ។

ខស្មានៈ ហើយក្រោយមកបានដឹងឬក៏ឃើញគាត់ត្រឡប់មកវិញទេ?

អ្នកជិតខាងៈ អត់ ។

ខស្មានៈ អត់ទេ?

អ្នកជិតខាងៈ បែបគេយកទៅចោលហើយ ។ ប្រហែលយកទៅកន្លែងហ្នឹងហើយ ។

ខស្មានៈ ចុះគ្រាន់តែចាប់ចង់អត់មានវាយដំអី នៅកន្លែងហ្នឹង?

អ្នកជិតខាងៈ អត់មានវាយមានដំអីទេប៉ុនចងគាត់ចងទាំងបន្ទា ។

ខស្មានៈ ឪ! ហើយមានតាហ្នឹង មាននិយាយប្រាប់សន្តិសុខថាយ៉ាងម៉េចវិញទេ?

អ្នកជិតខាងៈ គ្មាននិយាយប្រាប់ទេគ្រាន់តែផ្តាំយាយគាត់ថា ឲ្យយាយគាត់ខំធ្វើការទៅ គាត់ឡើងទៅតែប៉ុណ្ណឹងបាត់ ទៅតែម្តង ។ ឡើងរ៉ឺយទៅតែម្តងខោចង្កេះមួយ គាត់អត់មានបានអាវមានបានអីទេ?

ខស្មានៈ បាទ ហើយអឺគេបណ្តើរឬក៏មានឡានឬក៏មានម៉ូតូមានអីដឹកទេ?

អ្នកជិតខាងៈ គេបណ្តើរ គ្មានឡានទេ គេបណ្តើរឲ្យដើរ ។

ខស្មានៈ ឪ!

អ្នកជិតខាងៈ ដើរឃើតទៅគេប្រានទៅមុខទៀតទៅ ។

ខស្មានៈ បាទ ។

អ្នកជិតខាង៖ អើដើរៗទៅដល់យឺតទៅគេប្រានទៅ គេចាំទៅ ។

តា៖ ចាំតហើយគេវាយទៀតនោះ ។

ខស្មាន៖ បាទ ចុះតានោះតាមបងឃើញពីមុនមកគាត់ដូចថាមានកំហុសអីដែរ?

អ្នកជិតខាង៖ ដឹងមានកំហុសអីទេគាត់ចាស់ហើយនៅស្រុកហ្នឹង ហើយគាត់ផ្លាស់ទៅខ្ញុំនៅភូមិខ្ញុំនោះ ។

ខស្មាន៖ អត់ អត់ដឹងថា?

អ្នកជិតខាង៖ ហ្នឹងគាត់ គាត់ផ្លាស់ពីហ្នឹងទៅ ។

ខស្មាន៖ ផ្លាស់រយៈពេលប៉ុន្មានថ្ងៃ?

អ្នកជិតខាង៖ ផ្លាស់រយៈប៉ុន្មានជិតមួយខែណោះបាន បានគេចាប់គាត់ទៅ ។

ខស្មាន៖ នៅឯណោះភូមិអី?

អ្នកជិតខាង៖ នៅឯណោះខ្ញុំភូមិត្រកៀបក្តាម ។

ខស្មាន៖ ត្រកៀបក្តាម?

អ្នកជិតខាង៖ ចាស៎ ។

ខស្មាន៖ ឃុំអីឯណោះ?

អ្នកជិតខាង៖ ឃុំកំពង់ត្រាចដូចគ្នា ។

ខស្មាន៖ ឱ ឃុំកំពង់ត្រាចដែរ?

អ្នកជិតខាង៖ ចាស់ ប៉ុនគេផ្លាស់ឃុំណា ផ្លាស់ពីតាដក់ទៅត្រកៀបក្តាមចឹងណា ។

ខស្មាន៖ បាទៗ ។ បងខ្ញុំចង់សួរមួយចំណុចទៀតដូចថាជនជាតិក្រៅពីខ្មែរ ដូចជនជាតិចិន វៀតណាម ចាមអី មានមកដល់ភូមិហ្នឹង គេជំលៀសមកដល់ទេ?

តា៖ គ្មានទេ ។

ខស្មាន៖ ឬក៏មានវៀតណាមគ្រួសារវៀតណាមរស់នៅក្នុងភូមិហ្នឹងពីមុនមកទេសម័យខ្មែរក្រហមណា?

អ្នកជិតខាង៖ មិនដែលមានរស់នៅទេ ។ ទោះបើមាន បើមានគេយកទៅចោលព្រៃចកអស់ ។ បើមានចោលព្រៃចក អស់ ព្រៃចកហ្នឹង ។

ខស្មាន៖ តែមានទេនៅក្នុង?

អ្នកជិតខាង៖ មាន ។

ខស្មាន៖ មានដែរ?

អ្នជិតខាង៖ មានដូចថាចិនណា ។

ខស្មានៈ	ចិន?

អ្នកជិតខាងៈ	យួនគេយកទៅទាំងគូរ គេយកទៅចោលភ្លាមៗហ្នឹង ។

ខស្មានៈ	ឪ ចិនយួនហ្នឹងអ្នកស្រុកកំណើតនៅហ្នឹងឬក៏ជំលៀសពីកន្លែងផ្សេងមក?

អ្នកជិតខាងៈ	យកទៅវាយចោលអស់ហើយ យកទៅវាយចោលហ្នងហើយនៅក្នុងស្រុកក៏ដោយ ។

ខស្មានៈ	តែដូចយួនអីអ្នកយួនហ្នឹងកើតនៅហ្នឹង មានបងប្អូនស្រុកកំណើតនៅហ្នឹង ឬក៏ជម្លៀសពីកន្លែងផ្សេងមក?

អ្នកជិតខាងៈ	គ្មានទេ នៅហ្នឹងក៏ដោយឲ្យតែសាសន៍យួន ។

ខស្មានៈ	ឲ្យតែសាសន៍យួន?

អ្នកជិតខាងៈ	អីឲ្យតែសាសន៍យួន និងចិន មីងខ្ញុំកំពុងតែ មីងងំាៗដែលកំពុងនៅចុងព្រែកនោះមក ផ្លាស់តាហ្នឹងទៅ ចោលឯភូមិព្រៃចកដែរ ។ សម្រាលកូមកអើ ។

ខស្មានៈ	ឲ្យតែចិន?

អ្នកជិតខាងៈ	ឲ្យតែចិននិងយួន ។ យើប្ដីខ្មែរដោយសេរី គេដកដូចថាបើយើងយកប្ដីខ្មែរ គេដកប្រពន្ធ ទៅនៅប្ដីនៅខ្មែរ ទៅ ឆ្កុយទៅនៅប្ដីខ្មែរហ្នឹងណា៎ ។

ខស្មានៈ	ឧបមាយួនយកប្ដីខ្មែរ?

អ្នកជិតខាងៈ	អើ ដកយួនហើយនិងកូនយកទៅ ។

ខស្មានៈ	គេ គេ គេយក គេយកកូនហើយម៉ែ ម៉ែជនជាតិយួនហ្នឹង?

អ្នកជិតខាងៈ	ហ្នឹងហើយ ។

ខស្មានៈ	ហើយប្ដីនេះគេអត់យកទេ?

អ្នកជិតខាងៈ	អត់យកទេ ។ នៅឆ្កុយម្នាក់ឯងទៅ ។

ខស្មានៈ	ហើយចុះបើយួននោះហ្នឹងប្រុសវិញ យួនហ្នឹងជាប្ដី?

អ្នកជិតខាងៈ	យកទាំក្រុមគ្រួសារ ។

ខស្មានៈ	បាទ?

អ្នកជិតខាងៈ	យកទាំងពីនាក់ប្ដីប្រពន្ធទាំងកូនទៅទាំងអស់ ។

ខស្មានៈ	ឧបមានយួនហ្នឹងប្ដីជាជនជាតិយួន អីប្រពន្ធជនជាតិខ្មែរអាហ្នឹង?

អ្នកជិតខាងៈ	អាហ្នឹងយកប្ដី ។

ខស្មានៈ	យកប្ដី?

អ្នកជិតខាងៈ	ចាស់ ។

ខស្នានៈ ហើយចុះកូន?

គាៈ ដល់ប្ដីនិងកូនទៅទៀត ។

ខស្នានៈ កូនគេយកដែរ?

អ្នកជិតខាងៈ កូនគេយកដែរ ។

ខស្នានៈ អញ្ចឹងកូនកាត់ ទោះបីកាត់យ៉ាងម៉េចក៏គេយកទៅសម្លាប់ដែរ?

អ្នកជិតខាងៈ ទោះបីកាត់យ៉ាងម៉េចពូក៏យកដែរ ។

ខស្នានៈ ឱ!

អ្នជិតខាងៈ និយាយត្រង់ៗចឹងមិនយូរទេ បន្តិចគេចាប់ទៅបាត់ ។

ខស្នានៈ ចិនអញ្ចឹងដែរ?

អ្នកជិតខាងៈ ចាស់អញ្ចឹងដែរ ដូចគ្នា ដូចគ្នា ។

ខស្នានៈ នៅភូមិមានជនជាតិយួនប៉ុន្មាននាក់ដែលគេយកទៅ បងមានចាំបានទេ?

អ្នកជិតខាងៈ ទេមិនដឹងទេខ្ញុំមិនដឹងខ្ញុំនៅតែភូមិនខ្ញុំហ្នឹងហ្ន៎ ។ ហើយភូមិខ្ញុំផ្លាស់ពីកំពង់ត្រាច គេយកទៅ ។

ខស្នានៈ ឱផ្លាស់ពីកំពង់ត្រាចទេ?

អ្នកជិតខាងៈ ចាស់ផ្លាស់ពីកំពង់ត្រាចគេយកទៅ ។

ខស្នានៈ ឃើញយួនប៉ុន្មានគ្រួសារដែរគេយកទៅ?

អ្នកជិតខាងៈ កាលហ្នឹងប៉ុន្មានទេ មីង ឈ្មោះមីងអីមីងអីប៉ុន្មានបួនគ្រួសារគេផ្លាស់ទៅចូលខ្ញុំ ភូមិខ្ញុំឯត្រចៀកក្ដាមហ្នឹង អើគេផ្លាស់មក គេផ្លាស់មកគេក្នុងនោះឃើញគេយកទៅ គេបណ្ដើរទៅ ។ យំអើយយំ យំបែកប្ដីគាត់ គាត់ស្រឡាញ់ប្ដី គាត់ណាស់ ។ ហើយប្ដីគាត់នោះក៏យំបោកខ្លួនដែរ ។

ខស្នានៈ ពេលណាដែលគេយកជនជាតិយួនហ្នឹងទៅ ពេលហ្នឹងមានដូចថា ទើបតែចូលខ្មែរក្រហម ប្រជាជនភ្នំពេញទើបតែជំលៀសមកដល់ឬក៏ពេលចុងក្រោយនេះហើយ ។

អ្នកជិតខាងៈ ទេអាហ្នឹងមុនដូចផ្លាស់មកមុនមួយខែអញ្ចឹង គេមករើសយកចឹងតែម្ដង ។ ពីមុនអត់ មានមកទេ ។

ខស្នានៈ ឱពេល ពេលដែលគេទើបជំលៀសមកដល់អ្ហ៎?

អ្នកជិតខាងៈ ទើបនឹងគេផ្លាសដូចថា ផ្លាស់មកចឹងដូចបួនដប់ថ្ងៃ ម្ភៃថ្ងៃអីប្រធានគេដើរជំរើស យកថាអាណាចិន អាណាកាត់អីហ្នឹងគេគៀសយករបស់គេចឹងហ្មង ។

ខស្មានៈ អឺ ហើយអ្នកណាអ្នកដែលយកបុ អ្នកដែលយកហ្នឹងគេចុះមកពីលើដែរឬក៏?

អ្នកជិតខាងៈ ចុះមកពីលើបងគេចុះមកពីលើ មិនដឹងពីណាទេ មិនដឹង មិនដែលបានមើលគេចាប់ផង ។

ខស្មានៈ បាទចុះចិនគេយកដូចគ្នាចឹងដែរ?

អ្នកជិតខាងៈ គេយកដូចគ្នាចិនហើយនឹងយួនគេយកដូចគ្នា ។

ខស្មានៈ គេសំដៅលើចិនយ៉ាងម៉េចបើចិនខ្លះចេះនិយាយខ្មែរច្បាស់ដូចខ្មែរ?

អ្នកជិតខាងៈ ខ្មែរ ដូចតែគ្នាបរិភោគដូចតែគ្នាប៉ុនដូចថាគេយកចេញអញ្ចឹងហ្មង ។

ខស្មានៈ បាទ?

អ្នកជិតខាងៈ គេជ្រើសរើសយកចេញអញ្ចឹងហ្មង ។ គេជ្រើសរើសយើងយកចេញអញ្ចឹងហ្មង ។

ខស្មានៈ ឱ! អឺចាមដែលមានដំលៀសមកដល់ហ្នឹងទេ?

អ្នកចិតខាងៈ អត់មានចាមទេ ។

ខស្មានៈ អត់មានចាមអ្ហ៎?

អ្នកជិតខាងៈ មានតែចិនហើយយួន ។

ខស្មានៈ ខ្ញុំដូចអត់មានអីសួរបងទៀតទេហើយ ខ្ញុំអរគុណច្រើនដែលបងប្រាប់ឲ្យខ្ញុំបានដឹងរឿងរ៉ាវច្រើន ។ ហើយបងមានអីបន្ថែមទៀតដែរបង?

អ្នកជិតខាងៈ គ្មានទេ ។

ខស្មានៈ បាទអឺ បងខ្ញុំសុំស្គាល់ឈ្មោះបងផង?

អ្នកជិតខាងៈ ខ្ញុំ ខ្ញុំ?

ខស្មានៈ បាទ ។

អ្នកជិតខាងៈ ឈ្មោះអិន យឿង ។

ខស្មានៈ អិន យឿង?

អ្នកជិតខាងៈ ចាស់,

ខស្មានៈ អឺ បងអាយុប៉ុន្មាន?

យឿនៈ ខ្ញុំអាយុ៤៤ហើយ ។

ខស្មានៈ ៤៤ ប្រពន្ធរបស់បងប្រុសអ្ហ៎?

យឿងៈ ចាស់ហ្នឹងហើយប្រពន្ធ ។

ខស្មានៈ នៅភូមិ អឺត្រដក់?

យឿនៈ ចាស់ ។

ឧស្មានៈ គេហៅស្អីមួយទៀត?

គាៈ គេហៅត្រដក់ឈើភ្លើង?

ឧស្មានៈ បាទ?

យឿនៈ ហៅត្រដក់ឈើភ្លើងបញ្ចូលគ្នាហ្នឹងណា ។

ឧស្មានៈ ពាក្យភ្លើងយ៉ាងម៉េច?

យឿនៈ ចាស់..... ដុតក្បាលយើង ។ ភូមិឈើភ្លើង....ត្រដក់ ។

ឧស្មានៈ ឈើភ្លើងអ្ហ៎?

យឿនៈ ឈើភ្លើង ។

ឧស្មានៈ ឱ ឈើភ្លើង ។

យឿនៈ ឈើភ្លើងវាតិចគេចូលទៅណោះ ពីដើមវាច្រើន ។ ដល់ពីលិចមកអស់គេបញ្ចូល ។

ឧស្មានៈ បងដែលឮពីដំណើរការគេរៀបចំច្បាប់កាត់ទោសគេរៀបចំតុលាការកាតទោសខ្មែរក្រហមដែរ? ដែលឮទេ?

យឿនៈ អត់ដែលឮទេ ។

ឧស្មានៈ អត់ដែលឮទេ?

អ្នកជិតខាងៈ ដឹងតែជំនាន់ក្រោយទេ ។ ជំនាន់ចាស់ៗមុនណា ខ្មែរក្រហមឥស្សរៈជំនាន់ចាស់ ។

ឧស្មានៈ បាទ
អត់ទេគេសព្វថ្ងៃហ្នឹងគេរៀបចំកាត់ច្បាប់កាត់ទោសខ្មែរក្រហមតុលាការកាត់ទោសខ្មែរក្រហមណា៎

យឿនៈ អត់ដឹងផង ។

ឧស្មានៈ អត់ដឹងទេ?

យឿនៈ ចាស់ ។

ឧស្មានៈ ខ្ញុំជម្រាបបងអញ្ចឹះថា សព្វថ្ងៃដោយសារតែខ្មែរក្រហមមួយចំនួន មេដឹកនាំខ្មែរក្រហមដែលពាក់ព័ន្ធនឹងរឿងសម្លាប់អីហ្នឹងណា នៅរស់ ហើយរដ្ឋាភិបាលសហការជាមួយអង្គការសហប្រជាជាតិ អីរៀបចំតុលាការកាត់ទោសខ្មែរក្រហមហ្នឹង ។ ខ្ញុំអរគុណច្រើនបង ។

យឿនៈ ចាស ។